ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៥ លេខ០៩ ត្រីមាសទី០១ ឆ្នាំ២០២៥

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៤៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ និងទីប្រឹក្សាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១២រូប ១០២៧

២៧-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៤៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៣៤រូប ១០២៨

២៧-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៤៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ និងនិយោជិត នៃរដ្ឋាករទឹក ១៤រូប ១០៣០

២៧-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៤៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងកិច្ចការនារី ១៤រូប ១០៣១

*29-1-2025* *- NS/KRT/0125/150 NOMMONS à Son Excellence Monsieur Chang Jian Grand-Officier de l'Ordre Royal du Sahamétrei* ១០៣២

*29-1-2025* *- NS/KRT/0125/151 NOMMONS à Son Excellence Monsieur Wang Peng Grand-Officier de l'Ordre Royal du Sahamétrei* ១០៣៣

២៩-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៥៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ៤រូប ១០៣៤

២៩-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ដល់មន្ត្រីនគរបាលជាតិ ក្រសួងមហាផ្ទៃ ២រូប ១០៣៥

២៩-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦១ ស្ដីពី ការកំណត់ចំនួនចៅក្រមទាំងអស់នៃតុលាការកំពូល មិនឱ្យលើស ៣០ (សាមសិប) រូប ដោយរួមទាំងអនុប្រធាន និងប្រធានតុលាការកំពូលផង ១០៣៦

២៩-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងលោកជំទាវ ចំនួន ១៥រូប ១០៣៧

៣០-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦៥ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សា ឯកឧត្តម **ខង សូត** អនុប្រធានទី២ រដ្ឋសភា ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ១១រូប ១០៣៨

៣០-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់សប្បុរសជន ដែលបានរួមចំណែកជួយបរិច្ចាគធនធានផ្ទាល់ កសាងសមិទ្ធផលនានា ក្នុងវត្តឧណ្ណាលោម ខណ្ឌដូនពេញ រាជធានីភ្នំពេញ ៤រូប ១០៤០

៣១-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦៧ ស្ដីពី ការតែងតាំងមុខតំណែង ឯកឧត្តម **ឈៀង ពេជ្រ** ជាអនុរដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងប្រគល់ភារកិច្ចជូន លោកជំទាវ **សន សុភាវត្តី** ឋាននន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ១ នៃ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសាធារណការនិងដឹកជញ្ជូនឱ្យបំពេញមុខងារ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារកម្ម នៃក្រសួងសាធារណការនិងដឹកជញ្ជូន ១០៤១

៣១-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦៨ ស្តីពី ការដាក់លោក **ឆាយ គន្ធា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ តាមការស្នើសុំរបស់សាមីខ្លួន ១០៤២

៣១-១-២០២៥ -ព្រះរាជក្រឹត្យ នស/រកត/០១២៥/១៦៩ ស្តីពី ការតាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ៣រូប ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ១០៤៤


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៣-១-២០២៥ -អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ១០៤៦

៣-១-២០២៥ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ១០៦៦

២០-១-២០២៥ -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១០៧៦

២០-១-២០២៥ -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៧៨

២០-១-២០២៥ -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៨០

២០-១-២០២៥ -អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១០៨៣

២០-១-២០២៥ -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ១០៨៨

២០-១-២០២៥ -អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១០៩១

២០-១-២០២៥ -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៩៣

២០-១-២០២៥ -អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ១០៩៩

២០-១-២០២៥ -អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១១០១

២០-១-២០២៥ -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១១០៣


### ២~សេចក្តីសម្រេច


១៣-១-២០២៥ -សេចក្តីសម្រេចលេខ ០១ សសរ ស្តីពី ការបង្កើតគណៈកម្មការស្រាវជ្រាវនិងអភិវឌ្ឍន៍ ១១០៧

១៣-១-២០២៥ -សេចក្តីសម្រេចលេខ ០២ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល ១១១១

១៣-១-២០២៥ -សេចក្តីសម្រេចលេខ ០៣ សសរ ស្តីពី ការជ្រើសរើស ពលទាហាន ១១១៥


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៣-១-២០២៥ -ប្រកាសលេខ ០៧៩ សហវ.ប្រក.បគហ ស្តីពី ការបង្កើតអង្គភាពអនុវត្ត គម្រោងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ ១១១៧

២៣-១-២០២៥ -ប្រកាសលេខ ០៨០ សហវ.ប្រក.បគហ ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់ និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង-ហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ ១១២២

៤-៦-២០២៤ -ប្រកាសអន្តរក្រសួងលេខ ៣៤៥ សហវ.ប្រក.អថ ស្តីពី ការលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា នៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ១១២៦

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៣-៩-២០២៤ -ប្រកាសលេខ ៥៧៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លី លី ហ្វ៊ូដ អ៊ិនដាសទ្រី ខូអិលធីឌី បង្កើតរោងចក្រផលិតនំស្រួយ ទឹកដោះគោជូរ ទឹកសុទ្ធ ភេសជ្ជៈគ្រប់ប្រភេទ នំគ្រប់ប្រភេទ ស្ករគ្រាប់ បន្លែផ្លែឈើក្រៀម មី គុយទាវក្រៀម នំកញ្ចុកក្រៀម ស្រាកែច្នៃ ក្រដាសជូតមាត់ ក្រដាសរាម ក្រដាសវេចខ្ចប់ និងសំបកវេចខ្ចប់ប្រភេទប្លាស្ទិក ជ័រ ១១៤១

១៣-៩-២០២៤ -ប្រកាសលេខ ៥៧៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជផ្លាស ផេត ស៊ីបផ្លាយ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតតុក្កតា និងសម្ភារសត្វចិញ្ចឹម ១១៤៤

១៣-៩-២០២៤ -ប្រកាសលេខ ៥៧៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជាំងស៊ូ សេងបាង ហ្គាឌិន ហ្វើនីឈ័រ ឯ.ក បង្កើតរោងចក្រផលិតគ្រឿងសង្ហារិម ១១៤៧

១៣-៩-២០២៤ -ប្រកាសលេខ ៥៧៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហេង ស៊ុន ហាម៉ូនី (ខេមបូឌា) ហ្វុតវែរ ឯ.ក បង្កើតរោងចក្រផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ១១៥០

១៣-៩-២០២៤ -ប្រកាសលេខ ៥៧៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេចជី ម៉ីងហ៊ុយ អ៊ិនដាសស្ទ្រៀល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រខាត់អំបោះនិងជ្រលក់ពណ៌ ១១៥៣

១៣-៩-២០២៤ -ប្រកាសលេខ ៥៨០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីមជាលស៍ ខ្លូស៊ីង យូនីហ្វម (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ១១៥៦

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/ ១៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ និងទីប្រឹក្សា
ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១២រូបៈ

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១- ឯកឧត្តម សារុន ឫទ្ធា ២- ឯកឧត្តម ព្រហ្ម ដូលីន

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១- ឯកឧត្តម ដឹម ភ័ក្រ្តា ២- ឯកឧត្តម គួច ច័ន្ទក្រឹស្នា

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

ឯកឧត្តម ចាន់ សារ៉ែន

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

ឯកឧត្តម ឡាយ ណូរ៉ា

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១- ឯកឧត្តម ហុង វ៉ាដា ២- ឯកឧត្តម រស់ សោភា
៣- លោកជំទាវ ងួន សូនី ៤- ឯកឧត្តម ស៊ាង សុលក្ខណ៍
៥- ឯកឧត្តម អ៊ិន សាកាន ៦- លោកជំទាវ ញឹមខេមរា រូហ្សា

នរោត្តម សីហមុនី (ហត្ថលេខា)

៣១៧. ៤៥០១. ១៤៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ២៧ *ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានយកសេចក្តីគោរពតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ
នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៣៤រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម ពៅ វណ្ណដា
២- លោក រាម ច័ន្ទវណ្ណា
៣- លោក ខែម វីរៈ
៤- លោក ហ៊ិន សាង
៥- លោក ជា វុធឡុង
៦- លោក ឡុង សុខុម

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម កែវ សុជាតិ
២- លោក វ៉ាន់ ម៉ៅ
៣- លោក គង់ បញ្ញារិទ្ធ
៤- លោក ទឹង សេរីវុធ
៥- លោកស្រី ជុំ សុផា
៦- លោក ជូ ប៊ុនសៀង
៧- លោក សៀ គឹមហួន

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ឯកឧត្តម ង៉ែត វិបុល

ឃ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

១- លោក ជា វ៉ានី
២- លោក ប្រាក់ ចន្ទរ័ត្ន
៣- លោកស្រី ឆាយ ច័ន្ទនីរ៉ា
៤- លោកស្រី សន ចិន្តា
៥- លោក ឋា វុទ្ធី
៦- លោកស្រី គង់ សុចិត្ត
៧- លោកស្រី ស៊ីដា វិរិយា
៨- លោកស្រី ស៊ូ ចន្ទូ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | | |
|---|---|---|---|---|---|
| ៩- | លោក | សុខ ភីរ៉ា | ១០- | លោក | ប៉ែន សាវុធ |
| ១១- | លោក | វ៉ាត ផល្លា | ១២- | លោក | សឹង មុន្នីពិសិដ្ឋ |
| ១៣- | លោក | ប៉ាន់ សូណា | ១៤- | លោក | បុណ្យ សំណាង |
| ១៥- | លោកស្រី | ទិ ច័ន្ទថាឌី | ១៦- | លោក | អ៊ុន សុខហ៊ាង |
| ១៧- | លោក | ម៉យ សុខយ៉េម | ១៨- | លោក | ញ៉ែម សុវណ្ណ |
| ១៩- | លោកស្រី | ចៅ សុភាព | ២០- | លោកស្រី | ទេព សុភារី |

នស/រកត/០១២៥/១៤៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

នស/រកត/០១២៥/ ១៤៨

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **សុវត្ថារា** តាមលំដាប់ថ្នាក់
ដល់ថ្នាក់ដឹកនាំ និងនិយោជិត នៃរដ្ឋាករទឹក ១៤រូបៈ

ក-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | យន ណារិទ្ធ | ២- | លោក | ទុយ ណង |
| ៣- | លោក | ហ៊ឹម ស៊ីផាន់ | ៤- | លោកស្រី | ធឹង សុភា |
| ៥- | លោក | ក្លឹង វ៉ង់ជ្រឺឌី | ៦- | លោកស្រី | កូ ពេជាដា |
| ៧- | លោក | ម៉ក់ ហ៊ី | ៨- | លោក | ជុំ រ័ត្ន |
| ៩- | លោក | វ៉ាត វីរៈ | ១០- | លោក | ដៀប វណ្ណនី |

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | សូ សុវណ្ណារិទ្ធ | ២- | លោកស្រី | វណ្ណ សុសំនៀង |
| ៣- | លោក | ថាប់ សារ៉ា | ៤- | លោក | ជា ចាន់ដារ៉ា |

នរោត្តម សីហមុនី

៣៦០-៤៥០១.១៤៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្ស វិស្សុត**

នស/រកត/០១២៥/១៤៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងកិច្ចការនារី ១៤រូប៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១- លោកជំទាវ ឌី ក៉ានី        ២- លោក ស៊ុំ វណ្ណសាន

៣- លោក កី សុគន្ធ

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ ជា ហ៊ឹង        ២- លោកស្រី អ៊ុក ណាន្ធូ

៣- លោក ស៊ឹម សុផារិទ្ធ

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

លោកស្រី ចាន់ សាម៉ុឌី

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- លោកស្រី ដើក ហន        ២- លោក ជៀម គីមហួ

៣- លោកស្រី ប៉ែន គន្ធា        ៤- លោកស្រី ម៉េង គីមហួយ

៥- លោកស្រី ម៉ាលី សុខនី        ៦- លោកស្រី ឌុក ម៉ាឡានី

៧- លោក ហាវ សុវណ្ណ

ចរល. ២៥០១.១៤៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# KRET

NS / KRT / 0125 / 150

*Nous*

*Preah Karuna Preah Bat Samdech*

*Preah Boromneath Norodom Sihamoni*

*Roi du Cambodge*

## NOMMONS

*à*

*Son Excellence Monsieur Chang Jian*

*Grand-Officier de l'Ordre Royal du Sahamétrei*

នស.រកត.០១២៥.១៥០

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*Fait au Palais Royal, le 29 Janvier 2025*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ: ..០១៧/២៥.... រ.ចច

រាជធានីភ្នំពេញ ថ្ងៃទី ២៨.... ខែ មករា ឆ្នាំ ២០២៥

សម្តេចមហាមន្ត្រី គុយ សុផល

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# KRET

NS / KRT / 0125 / 151

*Nous*

*Preah Karuna Preah Bat Samdech*

*Preah Boromneath Norodom Sihamoni*

*Roi du Cambodge*

## NOMMONS

*à*

*Son Excellence Monsieur Wang Peng*

*Grand-Officier de l' Ordre Royal du Sahamétrei*

Norodom Sihamoni

ពារល . ២៥០១ . ១៥១

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*Fait au Palais Royal, le 29 Janvier 2025*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ: ០១៤ / ២៥ .... រ.ចច

រាជធានីភ្នំពេញ ថ្ងៃទី ២៩ .... ខែ មករា ឆ្នាំ ២០២៥

សម្តេចមហាមន្ត្រី គុយ សុផល

ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១២៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ៤រូប៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

លោកជំទាវ ធឹង ស៊ីមន

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម សែន កុសល

២-លោកជំទាវ រស់ សារុ

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ឯកឧត្តម សុះ ស៊ុបអ៊ី

នរោត្តមសីហមុនី

៣១ល . ២៥០១ . ១២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៥

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស **ជាតូបការ** ដល់មន្ត្រីនគរបាលជាតិ ក្រសួងមហាផ្ទៃ ២រូប៖

១-ឧត្តមសេនីយ៍ត្រី ឡោក ចន្ទា៉ អត្តលេខ ១៦១៨៩

២-ឧត្តមសេនីយ៍ត្រី ន៉ែ សុវណ្ណ អត្តលេខ ៦៦៩៦០

៣រល. ២៥០១. ១៦០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៥*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦១

ស្តីពី

## ការកំណត់ចំនួនចៅក្រមតុលាការកំពូល

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ត្រាស់បង្គាប់

**មាត្រា១ :** កំណត់ចំនួនចៅក្រមទាំងអស់នៃតុលាការកំពូល មិនឱ្យលើស ៣០ (សាមសិប) រូប ដោយរួមទាំងអនុប្រធាន និងប្រធានតុលាការកំពូលផង។

**មាត្រា២ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣រល. ២៥០១ . ១៦១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ២៨ *ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាសមាជិកទី១ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម)

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ជាតូបការ
- ១- ឯកឧត្តម និល ណុន
- ២- ឯកឧត្តម គង់ ស្រ៊ីម
- ៣- ឯកឧត្តម ឃួរ ឧត្តរា
- ៤- ឯកឧត្តម អ៊ុក គីមសិទ្ធិ
- ៥- ឯកឧត្តម ប្រាក់ គឹមសាន
- ៦- លោកជំទាវ គិម សត្ថាវី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍
- ១- ឯកឧត្តម សាលី ឆារ៉ា
- ២- ឯកឧត្តម យស់ សូខឿន
- ៣- ឯកឧត្តម អ៊ីវ គឹមស្រ៊ី
- ៤- ឯកឧត្តម សឹង បញ្ញាវុឌ្ឍ
- ៥- ឯកឧត្តម គង់ តារាឆាត
- ៦- ឯកឧត្តម ជុំ សំបាន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
- ១- ឯកឧត្តម ម៉ែត សារ៉ាត
- ២- ឯកឧត្តម ប៉ែន សារ៉ាត
- ៣- ឯកឧត្តម ម៉ូ ម៉ុនហាខ

នរោត្តមសីហមុនី

ពរល.២២៧.១៦២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ នាថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបោះ ឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា ឯកឧត្តម **ខេង សួត** អនុប្រធានទី២ រដ្ឋសភា ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ១១រូបៈ

| | |
|---|---|
| ១- ឯកឧត្តម **ម៉ៅ ម៉ុងលី** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២- ឯកឧត្តម **នង សុវណ្ណា** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៣- ឯកឧត្តម **ធន សុខសិដ្ឋ** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៤- ឯកឧត្តម **ហៀង សារ៉ា** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៥- ឯកឧត្តម **ជាយ ស៊ូដុង** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៦- ឯកឧត្តម **យិន ស៊ី** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៧- ឯកឧត្តម **ភាំង ប៉េងគីម** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ៨- លោកជំទាវ **សែមស័ក្តិ សុភាព** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៩- លោកជំទាវ **គឹម ហ៊ាង** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ១០- លោកជំទាវ **បាន សុធារៈ** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ១១- លោកជំទាវ **ផាត់ សុភា** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២** : សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣រល . ២៥០១ . ១៦៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ៣០ *ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានបង្ហាញតាមច្បាប់ដើម

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ដល់សប្បុរសជន ដែលបានរួមចំណែកជួយបរិច្ចាគធនធានផ្ទាល់
កសាងសមិទ្ធផលនានា ក្នុងវត្តឧណ្ណាលោម ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ក- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន**

ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោកជំទាវ **ខៀវ ស៊ីណា ជាចាន់តូ**

២- លោកជំទាវបណ្ឌិត **ជា សិរី**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តមសាស្ត្រាចារ្យ **Olivier de Bernon**

២- លោក **ឡេង កុករអាន**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ពរល.២៥០១.១៦៦

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៥*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: .....០១៥/២៥..... រ.ចច
រាជធានីភ្នំពេញ,ថ្ងៃទី ..៣០.. ខែ ..មករា.. ឆ្នាំ ២០២៥
សម្តេចមហាមន្ត្រី **គុយ សុផល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងមុខតំណែង ឯកឧត្តម **ឈៀង ពេជ្រ** ជាអនុរដ្ឋលេខាធិការនៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២** : ប្រគល់ភារកិច្ចជូន លោកជំទាវ **សន សុភាចន្ធី** អត្តលេខ ២៨៩១២០០០៧៧ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសុករកម្ម នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរល. ២៥០១. ១៦៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

Thoraxy

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ស្រាស់បង្គាប់

**មាត្រា ១ :** ដាក់លោក **ឆាយ គន្ធា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥។

**មាត្រា ២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

នស/រកត/០១២៥/១៦៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៥*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ សូមឡាយព្រះហស្តលេខា

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៥/១៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជសរកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ប្រកាស់បង្គាប់

**មាត្រា១** : តាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការ ០៣ រូប ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤ ៖

| | | |
|---|---|---|
| ១-លោក **នៅ ឧណ្ណេត** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ២-លោក **ស ចាន់ត្រា** | អនុមន្ត្រី | ថ្នាក់លេខ ១ |
| ៣-លោក **ពិសិដ្ឋ ពិទូរ្យ** | អនុមន្ត្រី | ថ្នាក់លេខ ១។ |

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នរោត្តមសីហមុនី

៣១៣.៤៤០១.១៦៩

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៥*

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម

**រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

Thongxy

បណ្ឌិតសភាចារ្យ **ហ៊ុន ថ្ងៃ៉ាអ៊ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកាគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ



៩

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ដែលមានឈ្មោះថា "**វិទ្យាស្ថានជាតិស្ថិតិ**" សរសេរជាអក្សរកាត់ថា "**វ.ជ.ស.**" និងសរសេរជាភាសាអង់គ្លេសថា National Institute of Statistics និងសរសេរជាអក្សរកាត់ថា "NIS" ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងផែនការ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២.-**

**វ.ជ.ស.** ជានីតិបុគ្គលនៃនីតិសាធារណៈ និងមានថវិកាស្វយ័ត ដែលត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងផែនការ។

**វ.ជ.ស.** មានទីតាំងបច្ចុប្បន្ននៅក្នុងទីស្តីការក្រសួងផែនការ ស្ថិតនៅផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

**មាត្រា៣.-**

**វ.ជ.ស.** មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិផ្លូវការ ក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិដែលរួមបញ្ចូលមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់ទាំងអស់និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន
- រៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ
- រៀបចំធ្វើជំរឿនប្រជាជន ជំរឿនសេដ្ឋកិច្ច និងជំរឿនកសិកម្ម
- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះ និងស្ថិតិផ្លូវការ តាមរយៈការធ្វើជំរឿន ការធ្វើអង្កេត ការសិក្សាស្រាវជ្រាវនានា និងការប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល ព្រមទាំងទិន្នន័យប្រភពផ្សេងៗទៀត ក្នុងគោលបំណង ដើម្បីប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ការធ្វើផែនការអភិវឌ្ឍន៍ និងការស្រាវជ្រាវ ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ

- ប្រមូល កែច្នៃ ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យស្ថិតិម៉ាក្រូសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់ទិន្នន័យដែលផ្តល់ឱ្យ ដោយអង្គភាពស្ថិតិផ្លូវការដែលបានចាត់តាំង នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចងក្រងស្ថិតិគណនេយ្យជាតិនិងស្ថិតិថ្លៃ ក៏ដូចជា សូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ប្រជាសាស្ត្រ ព្រមទាំងសន្ទស្សន៍និងសូចនាករស្ថិតិផ្សេងៗទៀត
- ស្រាវជ្រាវ សម្របសម្រួល ចងក្រងវិធីសាស្ត្រ បង្កើតនិងអភិវឌ្ឍន៍ម៉ូដែល និងបច្ចេកទេសស្ថិតិនានា ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ តាមបទដ្ឋានជាតិ និងអន្តរជាតិ
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងធនធានមនុស្ស សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និង អង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ
- សម្របសម្រួលប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព ផ្សព្វផ្សាយ ស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ
- រៀបចំចំណាត់ថ្នាក់ បទដ្ឋានស្ថិតិសម្រាប់ការអនុវត្តឯកភាពគ្នារបស់អង្គភាពស្ថិតិដែលបានចាត់តាំង
- អភិវឌ្ឍកម្មវិធីនិងបច្ចេកវិទ្យានៅក្នុងសកម្មភាពស្ថិតិដោយផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានវិទ្យា និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការផលិតទិន្នន័យ ការផ្ទេរនិងបញ្ចូលទិន្នន័យ ព្រមទាំង ការផ្សព្វផ្សាយទិន្នន័យស្ថិតិ និងសូចនាករអភិវឌ្ឍន៍
- ធ្វើកិច្ចសហប្រតិបត្តិការស្ថិតិជាមួយការិយាល័យស្ថិតិជាតិនៃបណ្តាប្រទេស អង្គការអន្តរជាតិ និងវិស័យឯកជននានា ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំងទាក់ទងនឹងស្ថិតិផ្លូវការ ដើម្បីលើកកម្ពស់ជានាការប្រតិបត្តិបទដ្ឋានស្ថិតិ ក្នុងការអនុវត្តគោលនយោបាយស្ថិតិ និងអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ
- សម្របសម្រួលក្នុងសកម្មភាពនៃដំណើរការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យស្ថិតិ ដោយរួមទាំងការផ្តល់ប្រឹក្សា និងជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- ប្រើប្រាស់ប្រភពទិន្នន័យធំ និងវិទ្យាសាស្ត្រទិន្នន័យ សម្រាប់ស្ថិតិផ្លូវការ ដោយរួមទាំងការផ្សព្វផ្សាយទិន្នន័យស្ថិតិផ្លូវការ តាមរយៈមធ្យោបាយឌីជីថល
- សហការផលិតស្ថិតិយេនឌ័រ និងចូលរួមការបញ្ជ្រាបស្ថិតិយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រមូលផ្តុំទិន្នន័យស្ថិតិផ្អែកតាមបទដ្ឋានស្តង់ដាជាតិ និងអន្តរជាតិសម្រាប់ផលិតសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)
- រៀបចំ និងចងក្រងចំណាត់ថ្នាក់ និងបទដ្ឋានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ចូលរួមផ្តល់ទិន្នន័យ និងវិភាគស៊ីជម្រៅអំពីភាពក្រីក្រនៅកម្ពុជា



៩

- រៀបចំជាអត្ថបទវិភាគ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងសង្គម សេដ្ឋកិច្ច បរិស្ថាន បច្ចេកវិទ្យា ពាណិជ្ជកម្ម ដោយប្រើប្រាស់ទិន្នន័យស្ថិតិគ្រឹះ និងទិន្នន័យរដ្ឋបាល ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង ស្ថាប័នរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ
- រៀបចំ និងអនុវត្តន៍យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយស្ថិតិផ្លូវការដើម្បីការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ ៣(បី) ឆ្នាំ និង ៥(ប្រាំ) ឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលរបស់ វ.ជ.ស.

**មាត្រា៤.-**

**វ.ជ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងាររបស់ **វ.ជ.ស.** ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីស្ថិតិ។

**មាត្រា៥.-**

ក្រុមប្រឹក្សាភិបាលនៃ **វ.ជ.ស.** មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន ១១ (ដប់មួយ)រូប ដែលមានសមាសភាពដូចតទៅ៖

- តំណាងក្រសួងផែនការ ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមុខងារសាធារណៈ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា សមាជិក
- តំណាងគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល សមាជិក
- នាយក **វ.ជ.ស.** សមាជិក
- តំណាងបុគ្គលិក **វ.ជ.ស.** សមាជិកស្ម័យប្រវត្តិ។

ក្រុមប្រឹក្សាភិបាលនៃ **វ.ជ.ស.** ត្រូវបង្កើតឡើងក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត **វ.ជ.ស.**។



៥

**មាត្រា៦.-**

តំណាងបុគ្គលិក **ទ.ជ.ស.** ១ (មួយ)រូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិកសម្រាប់អាណត្តិ ៣ (បី)ឆ្នាំ។ តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំងឡើយ។ នៅពេលចប់អាណត្តិ ឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សាភិបាល ដោយស្វ័យប្រវត្តិ។

តំណាងបុគ្គលិកត្រូវបានជ្រើសរើសដោយការបោះឆ្នោត ដែលប្រព្រឹត្តទៅតាមលក្ខណៈប្រជាធិបតេយ្យ។ អ្នកមានសិទ្ធិបោះឆ្នោត៖

ក. អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាល ជាបុគ្គលិកអចិន្ត្រៃយ៍។

ខ. អាណត្តិនៃក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទៀត ជាបុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោតតាមការសម្រេចរបស់ នាយក **ទ.ជ.ស.**។

តំណាងនេះត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ)ឆ្នាំ និងយ៉ាងច្រើន ៥៥(ហាសិបប្រាំ) ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្រ
- បម្រើការងារយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់ និង **ទ.ជ.ស.**
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់ តាមសំណូមពរ និងលក្ខខណ្ឌនៃការងាររបស់ **ទ.ជ.ស.**។

នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងបុគ្គលិកជាសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិនីមួយៗ នៃ **ទ.ជ.ស.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ នាយក **ទ.ជ.ស.**។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ក្រុមប្រឹក្សាភិបាលដទៃទៀត ត្រូវមានអាណត្តិ ៣(បី)ឆ្នាំ ដែលត្រូវបានតែងតាំង និងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័ន ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបន្តសាជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី ២ (ពីរ)អាណត្តិ ឡើយ។

**មាត្រា៧.-**

បេក្ខភាពជាក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ឬ ឥស្សរជនដែលមានលក្ខណៈសម្បត្តិ និងបទពិសោធន៍ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញាបត្រ
- បម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ នៅក្នុងក្រសួង ស្ថាប័ន ដែលខ្លួនតំណាង

- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈក្នុងវិស័យណាមួយ ដូចជា ស្ថិតិ សេដ្ឋកិច្ច ច្បាប់ ពាណិជ្ជកម្ម សង្គមកិច្ច និងគោលនយោបាយសាធារណៈ។

**មាត្រា៨.-**

សមាជិកភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់ មុនអាណត្តិតាមសំណើរបស់ក្រសួងស្ថាប័នតំណាងក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័នតំណាងបុគ្គលិករបស់ **ទ.ជ.ស.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត ១ (មួយ)ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាលចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងផែនការ ត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី។ ក្រសួងផែនការ ត្រូវទទួលខុសត្រូវលើភាពយឺតយ៉ាវនៃការស្នើតែងតាំងក្រុមប្រឹក្សាភិបាល។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមានបញ្ជាក់អំពីអាណត្តិ ដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មី ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរ ស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាល **ទ.ជ.ស.** មានវិសមិតភាពជាមួយមុខងារជានាយក **ទ.ជ.ស.**។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល **ទ.ជ.ស.** មានវិសមិតភាពមុខងារជាមួយសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជាបន្ទុករបស់ **ទ.ជ.ស.** លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាល មានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់ខ្ជាប់នូវគោលជំហររាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័ន ដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.ជ.ស.**។

**មាត្រា៩.-**

សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប នឹងទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភ ផ្សេងៗតាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនសមាជិកក្រុមប្រឹក្សាភិបាលនៃ **ទ.ជ.ស.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវបានផ្អាកដោយក្រសួង ស្ថាប័ន ដែលក្រុមប្រឹក្សាភិបាលម្នាក់ៗនោះតំណាងឱ្យ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះពុំគោរពអាណត្តិកិច្ចរបស់ខ្លួន ដែលមានជាអាទិ៍៖

- ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងមនសិការវិជ្ជាជីវៈ
- ការគោរពបទបញ្ជា និងបទប្បញ្ញត្តិរបស់ **ទ.ជ.ស.**
- ការបំពេញតួនាទី និងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល
- ការអនុវត្តកាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធមានជាអាទិ៍ ស្ថិតិ សេដ្ឋកិច្ច ច្បាប់ ហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងគោលនយោបាយសាធារណៈ និងតំណាងដៃគូអភិវឌ្ឍន៍ឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបានតាមការចាំបាច់។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា១០.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ និងតម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ទ.ជ.ស.** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ **ទ.ជ.ស.** ទាំងរយៈពេលមធ្យម ទាំងរយៈពេលវែង
- ពិនិត្យ និងអនុម័តយុទ្ធសាស្ត្រថវិកា គម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ទ.ជ.ស.**
- ពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រង **ទ.ជ.ស.** របាយការណ៍ចំណូលនិងចំណាយថវិការបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សមិទ្ធកម្ម របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ
- រៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **ទ.ជ.ស.**
- ជំរុញដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការ ដែលបង្កើតឡើងដោយអនុក្រឹត្យស្តីពីការបង្កើត **ទ.ជ.ស.**ព្រមទាំងបង្កើតគណៈកម្មាធិការ និងគណៈកម្មការនានា តាមការចាំបាច់
- កំណត់នូវនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ឬការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យ និងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់នាយក **ទ.ជ.ស.** ដោយដាក់ជូនរដ្ឋមន្ត្រីក្រសួងផែនការ ដើម្បីពិនិត្យនិងសម្រេច
- ធ្វើការវាយតម្លៃលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។



៩

**មាត្រា១១.-**

យ៉ាងយូរ ១ (មួយ)ខែក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង ដែលរបៀបវារៈសំខាន់ គឺការរៀបចំសេចក្ដីព្រាងប្រកាសអន្តរក្រសួងរវាងក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ **វ.ជ.ស.** ដែលក្នុងនោះ ត្រូវបញ្ជាក់ពីរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **វ.ជ.ស.**។

ក្រុមប្រឹក្សាភិបាល **វ.ជ.ស.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញតាមគំនិតផ្ដួចផ្ដើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២ភាគ៣ ឬពីនាយក **វ.ជ.ស.** តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យ និងការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្ម។

នាយក **វ.ជ.ស.** ត្រូវចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់ជាលេខាធិការនៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។ លេខាធិការនេះពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាល ធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការងារដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យថវិកា ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី ៥០(ហាសិប)ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមាន ពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមមិនគ្រប់គ្រាន់ នោះប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មី ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ ដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១(មួយ) ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ប្រធាន និងរក្សាទុកនៅទីស្នាក់ការរបស់ **វ.ជ.ស.** ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំ និងផ្ញើសេចក្ដីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល២(ពីរ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្ដល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលត្រូវចុះហត្ថលេខាលើកំណត់ហេតុ ដែលទទួលបានការកែសម្រួល ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើត្រូវបញ្ជូនក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវធ្វើឡើងជាចាំបាច់ ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ គឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិរបស់ ទ.ជ.ស.

**មាត្រា១២.-**

**ទ.ជ.ស.** ត្រូវគ្រប់គ្រងដោយនាយក ១(មួយ)រូប ដែលត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ នាយក **ទ.ជ.ស.** មានតួនាទីជានាយកប្រតិបត្តិ ហើយការតែងតាំងនាយក ត្រូវធ្វើឡើងយ៉ាងយូរ ១(មួយ)ខែ ក្រោយពីការចូលជាធរមាននៃអនុក្រឹត្យនេះ។

មុខងារជានាយក **ទ.ជ.ស.** មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។

យ៉ាងយូរ ១(មួយ)ខែ ក្រោយការតែងតាំងនាយក **ទ.ជ.ស.** ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

**មាត្រា១៣.-**

នាយក **ទ.ជ.ស.** ជាតំណាងរបស់ **ទ.ជ.ស.** ក្នុងទំនាក់ទំនងជាមួយតតិយជន។

នាយក **ទ.ជ.ស.** មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ **ទ.ជ.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ទ.ជ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រង **ទ.ជ.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អនុវត្តថវិការបាយការណ៍សមិទ្ធកម្ម របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់ **ទ.ជ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត

- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់នូវភារកិច្ចរបស់អង្គភាពចំណុះនានានៃ **ទ.ជ.ស.**
- លើកសំណើរៀបចំចេនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ ការជ្រើសរើស និងចំនួនមន្ត្រីរាជការនិងបុគ្គលិកជាប់កិច្ចសន្យារបស់ **ទ.ជ.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយដទៃទៀត ដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

នាយក **ទ.ជ.ស.** មានសិទ្ធិស្នើទៅក្រសួងផែនការ សុំតែងតាំងនាយករង ១ (មួយ)រូប ឬច្រើនរូប ជាជំនួយការ ដោយអនុលោមតាមបទដ្ឋានគតិយុត្តជាធរមាន។ នាយករង ត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗ ដែលត្រូវទទួលគ្រប់គ្រង។

## ផ្នែកទី៣
## បុគ្គលិករបស់ ទ.ជ.ស.

**មាត្រា១៤.-**

បុគ្គលិកអចិន្ត្រៃយ៍របស់ **ទ.ជ.ស.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង **ទ.ជ.ស.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ទ.ជ.ស.** អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងមន្ត្រីប្រភេទផ្សេងទៀត ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់ **ទ.ជ.ស.** ត្រូវស្ថិតក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្តីពីបុគ្គលិក ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅ **ទ.ជ.ស.** ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិកាជាតិស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការដ្ឋជូនបុគ្គលិកអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យារបស់ **ទ.ជ.ស.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់នាយក **ទ.ជ.ស.** បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់ ទ.ជ.ស.

**មាត្រា១៥.-**

**ទ.ជ.ស.** ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ទ.ជ.ស.** មានទ្រព្យសម្បត្តិ ដែលរួមមាន៖

ក. ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្ដីពីការបង្កើត **ទ.ជ.ស.** នេះ ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួង រវាងក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាពនិងចុះហត្ថលេខាពីក្រសួង ស្ថាប័នអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា។

ខ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលអាចរកបានក្រោយថ្ងៃបង្កើត **ទ.ជ.ស.** ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ទ.ជ.ស.** ត្រូវបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **ទ.ជ.ស.** ។ នាយក **ទ.ជ.ស.** ដែលជាប្រធាន និងសមាជិកដទៃទៀតនៃគណៈកម្មការនេះ ត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ដោយអនុលោមទៅតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ទ.ជ.ស.** មានកាតព្វកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរនៅចុងត្រីមាសទី១ (មួយ) នៃឆ្នាំបន្ទាប់។

**ទ.ជ.ស.** អាចធ្វើការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យ លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែល **ទ.ជ.ស.** ត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយអនុក្រឹត្យ ទ្រព្យសកម្មដែលជាចលនទ្រព្យ និងអចលនទ្រព្យរបស់ **ទ.ជ.ស.**ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុ ត្រូវបង្វែរចូលគណនីទោលរតនាគារ។

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ទ.ជ.ស.

**មាត្រា១៦.-**

**ទ.ជ.ស.**ត្រូវមានគណនេយ្យភាពចំពោះក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៧.-**

នាយក **ទ.ជ.ស.** ជាអាណាប័កផ្ទេរសិទ្ធិស្វ័យប្រវត្តិនៃថវិការបស់ **ទ.ជ.ស.** ដែលទទួលបានការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងផែនការ ដែលជាអាណាប័កដើមខ្សែ មានសិទ្ធិអំណាចដូចតទៅ៖

- បញ្ជា និងជម្រះចំណូល
- ធ្វើប្រតិបត្តិការចំណាយស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនិងហិរញ្ញវត្ថុជាធរមាន។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ នាយក **ទ.ជ.ស.** អាចផ្ទេរសិទ្ធិនេះឱ្យអាណាប័កជំនួស ក្នុងករណីអវត្តមាន ឬមានធុរៈ ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវជូនដំណឹងទៅអ្នកត្រួតពិនិត្យថវិកា គណនេយ្យករប្រចាំ **ទ.ជ.ស.** និងទៅរដ្ឋមន្ត្រីក្រសួងផែនការ មានការយល់ព្រមពីអាណាប័កដើមខ្សែ។

ក្រសួងផែនការ ត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ទ.ជ.ស.** តាមសំណើរបស់ នាយក **ទ.ជ.ស.** និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ **ទ.ជ.ស.** ។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រឡើងទៅ ផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣(បី)ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីគណនេយ្យត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករ ត្រូវមានគុណវុឌ្ឍិ និងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់ ព្រមទាំងបំពេញលក្ខខណ្ឌផ្សេងទៀត ដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណនេយ្យករត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យករត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់។

គណនេយ្យករ មានភារកិច្ច ៖

- ទទួល និងគ្រប់គ្រងចំណូល
- ទូទាត់ចំណាយ
- រក្សាទុកដាក់ និងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ
- រៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **ទ.ជ.ស.** ។

គណនេយ្យករអាចមានមន្ត្រីជំនាញមួយចំនួន ជាជំនួយការគណនេយ្យក្នុងការបំពេញមុខងាររបស់ខ្លួន។

**មាត្រា១៩.-**

ប្រភពធនធានរបស់ **ទ.ជ.ស.** រួមមាន៖



9

- ធនធានដំបូងរបស់រដ្ឋផ្តល់ជូន **ទ.ជ.ស.** នៅពេលចាប់ផ្តើមបង្កើតដំបូង ស្របតាមមាត្រា១៥ នៃអនុក្រឹត្យនេះ
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានគ្រោងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនសម្រាប់ ដំណើរការ និងឧបត្ថម្ភធនជាមូលធន
- អំណោយ ជំនួយ និងអច្ច័យទានដែល **ទ.ជ.ស.** បានទទួល
- កម្រៃសេវាសាធារណៈ ឬភាគទានដែល **ទ.ជ.ស.** មានសិទ្ធិប្រមូល ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់ **ទ.ជ.ស.** និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះ ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២០.-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់ **ទ.ជ.ស.** ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.** និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិកាក្រសួងផែនការ។ ចំណូលរបស់ **ទ.ជ.ស.** រួមមាន ការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗ ស្របតាមមាត្រា១៩ នៃអនុក្រឹត្យនេះ។

ថវិកាត្រូវរៀបចំដោយ នាយក **ទ.ជ.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងផែនការ ដើម្បីពិនិត្យនិងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ថវិកាត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ចំណូល និងចំណាយរបស់ **ទ.ជ.ស.** ត្រូវគោរពតាមលំនាំដូចគ្នាទៅនឹងវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិកាថ្នាក់ជាតិដែរ។

ចំណាយត្រូវឆ្លុះបញ្ចាំងគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

**ទ.ជ.ស.** មិនអាចបង្កើតលក្ខខណ្ឌ ដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២១.-**

គណនេយ្យរបស់ **ទ.ជ.ស.** រួមមាន៖

- គណនេយ្យថវិកា
- គណនេយ្យទូទៅ ដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការជាសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

កិច្ចបញ្ជិកាគណនេយ្យរបស់ **ទ.ជ.ស.** ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ទ.ជ.ស.** ត្រូវអនុវត្តកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូល តាមគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានជាធរមាន។



៩

**មាត្រា២២.-**

ថវិការបស់ **ទ.ជ.ស.** ជាមូលនិធិសាធារណៈរបស់រដ្ឋ។

ថវិការបស់ **ទ.ជ.ស.** ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យ **ទ.ជ.ស.**ប្រើប្រាស់គណនីនៅធនាគារពាណិជ្ជ សម្រាប់គ្រប់គ្រងថវិកាដែលបានមកពីចំណូលផ្ទាល់ និងពីប្រភពផ្សេងៗទៀត។

អតិរេករបស់ **ទ.ជ.ស** អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយប្រតិបត្តិការនាការិយបរិច្ឆេទបន្ទាប់ និង/ឬសម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍរបស់ **ទ.ជ.ស.** ផ្ទាល់ ឬជាកម្មវត្ថុនៃការបង់ចូលថវិកាថ្នាក់ជាតិ។ ការស្នើសុំប្រើប្រាស់អតិរេកនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុនបញ្ជូនទៅក្រសួងផែនការដើម្បីពិនិត្យ និងសម្រេច និងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។

## ផ្នែកទី៦
## របបសារពើពន្ធរបស់ ទ.ជ.ស.

**មាត្រា២៣.-**

**ទ.ជ.ស.** ត្រូវស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់។

## ផ្នែកទី៧
## ការធានាលទ្ធកម្មរបស់ ទ.ជ.ស.

**មាត្រា២៤.-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង **ទ.ជ.ស.** ត្រូវអនុលោមតាមច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## អាណាព្យាបាលភាព

**មាត្រា២៥.-**

**ទ.ជ.ស.** មានក្រសួងផែនការ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាណាព្យាបាលហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានថវិកាជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រង **ទ.ជ.ស.** ។

**មាត្រា២៦.-**

អាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ចសវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់ **ទ.ជ.ស.** តាមការចាំបាច់។

**មាត្រា២៧.-**

**ទ.ជ.ស.** ត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យថវិកាប្រចាំ **ទ.ជ.ស.** ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាលលើឯកសារដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍ **ទ.ជ.ស.**
- ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.**
- របាយការណ៍គ្រប់គ្រង **ទ.ជ.ស.** របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្មរបស់ **ទ.ជ.ស.**។

ទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យថវិកាប្រចាំ **ទ.ជ.ស.** ត្រូវចាត់ការតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៨.-**

អាណាព្យាបាលបច្ចេកទេស មានភារកិច្ចដូចខាងក្រោម៖

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ **ទ.ជ.ស.** អនុវត្ត
- ពិនិត្យ និងសម្រេចផែនការអភិវឌ្ឍន៍របស់ **ទ.ជ.ស.**
- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.**
- ពិនិត្យ និងសម្រេចលើសំណើចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់ **ទ.ជ.ស.**
- ដាក់ចេញនូវវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់ **ទ.ជ.ស.**
- ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធគ្រប់គ្រងនៃ **ទ.ជ.ស.**
- ស្នើតែងតាំងនាយក **ទ.ជ.ស.**
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅ **ទ.ជ.ស.** អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ **ទ.ជ.ស.**។

**មាត្រា២៩.-**

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរនូវការសម្រេចទាំងឡាយរបស់ខ្លួន និងរបស់ក្រុមប្រឹក្សាភិបាល ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យ និងសម្រេច មានជាអាទិ៍៖

- ផែនការអភិវឌ្ឍន៍ **ទ.ជ.ស.**
- ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.**
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ចំណូលនិងចំណាយថវិកា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម
- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀតដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

**មាត្រា៣០.-**

អាណាព្យាបាលបច្ចេកទេស មានសិទ្ធិលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹង **ទ.ជ.ស.** ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ទ.ជ.ស.** ផ្ទុយនឹងគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់ **ទ.ជ.ស.** ក៏ដូចជាក្រសួងផែនការ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ទ.ជ.ស.** ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរ ដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬសេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាល ដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងផែនការត្រូវជូនដំណឹងអំពីប្រកាសនេះដល់នាយក **ទ.ជ.ស.**។ នាយក **ទ.ជ.ស.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៣១.-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ឬនាយក **ទ.ជ.ស.** ពុំប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.ជ.ស.** ក្រសួងផែនការអាចចេញសេចក្តីសម្រេច និងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា៣២.-**

អាណាព្យាបាលហិរញ្ញវត្ថុ មានភារកិច្ច៖

- ពិនិត្យ និងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍របស់ **ទ.ជ.ស.**
- ពិនិត្យ និងសម្រេចលើផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ជ.ស.**
- ពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់ **ទ.ជ.ស.**
- ពិនិត្យ និងសម្រេចលើការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ

- ពិនិត្យ និងផ្តល់ការយល់ព្រមលើរបាយការណ៍ចំណូល និងចំណាយថវិកា របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ
- ពិនិត្យ និងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យ និងសម្រេច ឬផ្តល់ការយល់ព្រមលើឯកសារផ្សេងទៀត តាមសំណើរបស់ក្រសួងផែនការ ឬ នាយក **ទ.ជ.ស.** ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និង បទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ **ទ.ជ.ស.**។

**មាត្រា៣៣.-**

សេចក្តីសម្រេចរបស់នាយក **ទ.ជ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៣២ នៃអនុក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងនាយក **ទ.ជ.ស.** នូវការជំទាស់របស់ខ្លួន ដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ នាយក **ទ.ជ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យ និងដោះស្រាយឱ្យបានឆាប់បំផុត នូវករណីដែលបានលើកឡើងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣៤.-**

អាណាព្យាបាលហិរញ្ញវត្ថុអាចលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុ របស់នាយក **ទ.ជ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់នាយក **ទ.ជ.ស.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកទុកនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេស និងនាយក **ទ.ជ.ស.** ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

## ជំពូកទី៤
## ការត្រួតពិនិត្យ

**មាត្រា៣៥.-**

**ទ.ជ.ស.** ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។



៩

**មាត្រា៣៦._**

**ទ.ជ.ស.** ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច សវនកម្ម តាមដាន និងត្រួតពិនិត្យដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ស្របតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ **ទ.ជ.ស.** អាចត្រូវបានតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្ម ដោយសវនករឯករាជ្យដែលមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៣៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៨._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥កើត ខែ បុស្ស ឆ្នាំរោងឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា គ.ស. ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន **២២១ រូប** ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក **សា សុខ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២-ឯកឧត្តម **ចឹក លីម** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣-លោក **ផាត តាំងស៊្រុន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤-លោក **ឈិន សៅរ៍សេកវាជ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៥-លោកស្រី **សូត សុតបញ្ញា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៦-លោក **កៅ សុវណ្ណតារា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៧-លោក **មឿន សុខសាន្ត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៨-លោក **ពៅ សុផល** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៩-លោក **ខឿន អ៊ី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១០-លោក **សែន សេរី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១១-លោក **សូ ស៊ីណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១២-លោក **មាឃ សាម៉ន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៣-លោក **សាន់ សុផារិទ្ធ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៤-លោក **កែម សើន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៥-លោក **លិន តារា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៦-លោក **សៀខ យុទ្ធី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៧-លោក **ស៊ិន គីមនួន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៨-លោក **សុខ បូរ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ១៩-លោក **សុវណ្ណ រដ្ឋា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២០-លោក **ញាណ សំបូណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២១-លោក **ម៉ក់ សុផាត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២២-លោក **ហោ គុណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៣-លោកស្រី **ស៊ឹម ស៊ីណាត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៤-លោកស្រី **ឃាន សុតាព** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៥-លោកស្រី **គឹម ផល្លា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៦-លោក **ហាម ដារ៉ូ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ២៧-លោក **លុក សំណាង** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ២៨-លោក **ឃូ ហាច** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ២៩-លោក **គ្រុយ គ្រឿន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣០-លោក **នេខ បូរិទ្ធិ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣១-លោក **ភាក់ សុខគី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣២-លោក **បែន ដាលី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៣-លោក **ហៃ និចសុន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៣៤-លោក **ឡាយ សុខជា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៥-លោក **ហាង់ ពិសិដ្ឋ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៦-លោក **ជ សេរីវុឌ្ឍ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៧-លោក **អាត សារ៉េត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៨-លោក **ស៊ាន ផល្លា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៣៩-លោក **អ៊ុន ណារុន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤០-លោក **ជា បញ្ញា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤១-លោក **ឈូក ច័ន្ទឆាយា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤២-លោក **ឡុង ឌីណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៣-លោក **គិត ម៉េងហ៊ុន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៤-លោក **តោគ ចន្ធី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៥-លោក **ខន ធារ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៦-លោក **មាង មឿន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៧-លោក **ស៊ុត សុវណ្ណារ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៨-លោក **សេង គីមហួ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៤៩-លោក **ប្រាក់ វិសាល** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥០-លោក **ស៊ុន តេម** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥១-លោក **រី សុគាំ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥២-លោក **សុខ វណ្ណៈ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៣-លោក **ទ្រឹម ពីណូរ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៤-លោក **លី សីណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៥-លោក **សុខ សុភា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៦-លោក **លឹម វិបុល** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៧-លោក **យ៉េន សីម៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៨-លោក **ឡាយ សាវ៉ាន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៩-លោក **ម៉ូ សុគន្ធ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦០-លោក **ម៉ៅ ប៊ុនថេរ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦១-លោក **ឆាញ ធឿន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦២-លោក **ម៉ិច សុរិយា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៣-លោក **ឡាច វិបុល** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៤-លោក **ម៉ឹង ម៉ាឡុន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៥-លោក **តោគ តុលា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៦-លោក **ហែម វិសុទ្ធ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៧-លោក **ភុល ថាន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៨-លោក **ញឹក ភិត្យា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៩-លោក **អ៊ុំ រតនា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧០-លោក **ឡាច តាស់** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |



ម

| | | |
|---|---|---|
| ៧១-លោក **សេង សុវណ្ណរតន៍** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧២-លោក **ឆន តារី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៣-លោក **ម៉ាច សុភត្ត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៤-លោក **ស្ងួស ភក្តី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៥-លោក **ស៊ុំ សុខឿន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៦-លោក **សេង មុនី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៧-លោក **គៀន ថាល់** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៨-លោក **សោ គន្ធា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៩-លោក **ហឿង ផេន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨០-លោក **រស់ សុភាន់** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨១-លោក **ជា សុទ្ធ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨២-លោក **សុខ សិរីវឌ្ឍនា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៣-លោក **ឡុច ស៊ីនាង** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៤-លោក **ទ្រី ចន្ទ្រា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៥-លោក **ពេជ្រ សុភ័ក្រ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៦-លោក **ដុក ភ័ក្ត្រា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៧-លោក **អ៊ិន អាន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៨-លោក **ដៃ សំពិសាល** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៩-លោក **ហេង មករា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩០-លោក **ប៊ាន សុម៉ាច** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩១-លោក **សាន សុភី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩២-លោក **អម វណ្ណា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៣-លោក **ពៅ បូរិត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៤-លោក **ទ៉ា ទិដ្ឋា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៥-លោក **នុត ចន្ថា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៦-លោក **លី ឆេងហួ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៧-លោក **ត្លូច ធនុជ័យ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៨-លោក **កែវ មុន្នីសុវណ្ណ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៩-លោក **ទូច ចាន់ឡា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០០-លោក **ឡុង ចំរើន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០១-លោក **ចែម ឆក** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០២-លោក **ទ៉ាយ សុធា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០៣-លោកស្រី **សុខ ផល្លី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០៤-លោកស្រី **សៅ សុគន្ធា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០៥-លោកស្រី **សោម ពិសី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០៦-លោកស្រី **សៀ សុជាតា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ១០៧-លោកស្រី **វង់ សុខុម** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

១០៨-លោកស្រី **ម៉ិច វណ្ណារ៉ាវី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១០៩-លោកស្រី **ជិត ម៉ាលីន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១០-លោកស្រី **អ៊ិន ច័ន្ទមល្លិកា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១១-លោកស្រី **ទិព្វ សារី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១២-លោកស្រី **អោល ចារ** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៣-លោកស្រី **អ៊ីុង ស៊ីុវហ្គេច** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៤-លោកស្រី **គង់ ស្រីពៅ** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៥-លោកស្រី **ហ៊ុន ចិន្តា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៦-លោកស្រី **សំ ពិសី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៧-លោកស្រី **រុន សុចន្ទណា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៨-លោកស្រី **សុខ ចន្ធី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១១៩-លោកស្រី **វ៉ាង គីមពូន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២០-លោកស្រី **ស៊ាត សុភា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២១-លោកស្រី **យុត មាសម៉ានី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២២-លោកស្រី **បាត់ ស្រីខួច** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៣-លោកស្រី **គ្រួច សោភា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៤-លោកស្រី **ឃឹម ដារ៉ានី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៥-លោកស្រី **សៀង លីនដា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៦-លោកស្រី **ស្រៀង លាងឆេង** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៧-លោកស្រី **ភេត ធីតា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៨-លោកស្រី **ជាម សុភា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
១២៩-លោក **រស់ សាន់តាណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣០-លោក **សុខ សុងហៃ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣១-លោក **លុន ហ៊ាប** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣២-លោក **សែម ម៉ាក់** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣៣-លោក **គង់ ក្រេម** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣៤-លោក **ហៀង ណោន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣៥-លោក **សំរិទ្ធ វិចិត្រ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៣៦-លោក **លី សាក់រ៉េនី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៣៧-លោក **កែវ សោភ័ណ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៣៨-លោក **យ៉ុង យ៉ុន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៣៩-លោក **អ៊ួន ទ៉ាន់ឡឿន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤០-លោក **ហ៊ាន រ៉ាវី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤១-លោក **ប៉ាន់ សុភក្ត្រា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤២-លោក **ម៉េង លីនណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៣-លោក **តាំ តើត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៤-លោក **ចាន់ ផា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៥-លោក **ឡាំង ឈាងហេង** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៦-លោក **ភឿង ប៊ុនថន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៧-លោក **ម៉ាន ម៉ាហៀត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៨-លោក **អឿង សុភាស់** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៤៩-លោក **ផល ចេក** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥០-លោក **ឡេង ដា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥១-លោក **សល់ឡេះ យូសុះ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥២-លោក **រ័ត្ន សូរិយា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥៣-លោក **កែវ មករា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥៤-លោក **ខាម សុភីរុំ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៥៥-លោក **ទ៉ាន់ ថៃ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

| | |
|---|---|
| ១៥៦-លោក **នួន ទាសនា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៥៧-លោក **ឆាន ពិសិដ្ឋ** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៥៨-លោក **ទ៉ា សុភ័ក្ត្រា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៥៩-លោក **ពេជ្រ សម្បត្តិ** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦០-លោក **ហួន សុសឆា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦១-លោក **ស្រី សំណាង** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦២-លោក **និត្យ ឥត្តី** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៣-លោក **សេក ពិសី** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៤-លោក **រិន សុវណ្ណារ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៥-លោក **សាន ម៉ានិត** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៦-លោក **ហ៊ីន់ ហ៊ុម** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៧-លោក **ស៊ួស សាហាន** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៨-លោក **ទ៉ាន់ ចាន់មុន្នី** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៩-លោក **គៀន ពន្លក** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧០-លោក **ទូច សុខៈ** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧១-លោក **ចេង ចាន់ធឿន** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧២-លោក **គុយ វិចិត្រ** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧៣-លោក **អ៊ឹម សិរីរដ្ឋ** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧៤-លោក **គង់ ទាសនា** | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១<br>មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |

១៧៥-លោក **ម៉ម អានី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៧៦-លោក **ប៉ាង បុណ្ណារិទ្ធ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៧៧-លោក **ប៉ាច សុវណ្ណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៧៨-លោក **ច៉ក់ ផល្លា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៧៩-លោក **សា ឥស្លាមី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨០-លោក **លី រ៉ស៊ីឌី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨១-លោក **ហាម បុរី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨២-លោក **អ៊ាច សំអុន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៣-លោក **អ៊ឹម សាម៉ែន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៤-លោក **ម៉ុំ គីមសាត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៥-លោក **ទិន វណ្ណារិទ្ធ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៦-លោក **យុត ឫទ្ធីរត្ន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៧-លោក **ឡឹក សុធាណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៨-លោក **ម៉ាត់ អាល់ពី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៨៩-លោក **ឯក ឡេងហោ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៩០-លោក **ចេង គីមអាន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៩១-លោក **វ៉ាន់ ទី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៩២-លោក **មាស ឡេន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៩៣-លោក **ឈន់ អេងលី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៤-លោក **សុទ្ធ រ៉ូដាភូ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៥-លោកស្រី **ខាត់ សារ៉េត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៦-លោកស្រី **ឡឹយ សុគា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៧-លោកស្រី **ពុធ ឥ័ស្តតា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៨-លោកស្រី **ខាន់ ម៉ាឡា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩៩-លោកស្រី **សេន ហ្វាហ៊ីម៉ី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០០-លោកស្រី **យ៉ា ច័ន្ទសុធា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០១-លោកស្រី **សាក់ ស្រីម៉ុន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០២-លោកស្រី **ជា ស្រីម៉ៅ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៣-លោកស្រី **គន គឹមលន់** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៤-លោកស្រី **ហ្វូ គឹមហៀក** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៥-លោកស្រី **លី អាហ្សីហ្សា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៦-លោកស្រី **ហៃ សុខអេង** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៧-លោកស្រី **មឿង ស៊ិនស្រីរ័ត្ន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៨-លោកស្រី **កែវ រស្មី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០៩-លោកស្រី **សេង សារ៉ា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១០-លោកស្រី **ម៉ិល សុខសាន្ត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១១-លោកស្រី **នោះ សុខន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១២-លោកស្រី **ខ៉ាម សុផាណ្ណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៣-លោកស្រី **ឡើន ដាវីន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៤-លោកស្រី **ទូច ចន្ធូ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៥-លោកស្រី **ថុខ សុភាព** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៦-លោកស្រី **មិន សុខណា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៧-លោកស្រី **គុំ ម៉ុន្ថា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៨-លោកស្រី **ធីម ឌួចឡា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១៩-លោកស្រី **ជា សុខេមា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២២០-លោកស្រី **អោម សុខុម** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២២១-លោកស្រី **អ៊ុច ធារី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤។

**មាត្រា២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ១០រូប ដែលបានបរិច្ចាគធនធានចូលរួមកសាងសមិទ្ធផលនានាក្នុងវត្តអង្គសីម្ពលី និងវត្តខ្ពប ព្រមទាំងបានចូលរួមអភិវឌ្ឍក្នុងមូលដ្ឋាន ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- លោកវេជ្ជបណ្ឌិត ឡេវ ចំរើន
២- លោក កុក លីយស
៣- លោក តឹក កក្កដា
៤- លោក ប៉ូវ នី
៥- លោកស្រី ហេង ធរី
៦- លោក ទឹម ផន

| | |
|---|---|
| ៧- លោក | សុខ ប៊ុនវីរៈ |
| ៨- អ្នកស្រី | ម៉ៅ សុភាព |
| ៩- លោកអាចារ្យ | ទិត គឿន |
| ១០- ឧបាសិកា | កុល រុំ ។ |

**មាត្រា២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧ រោច ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តអង្គកែវ ឃុំអង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ កន្លងមក ដូចមានរាយនាមខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | លោកស្រី | ឡាយ កន្និកា | សប្បុរសជន |
| ២- | លោក | រៀម ធារ៉ាដាវីត | សប្បុរសជន |
| ៣- | លោក | គង់ សុវណ្ណារិទ្ធិ | សប្បុរសជន |
| ៤- | លោក | ញ៉ែម អង្គារ័ត្ន | សប្បុរសជន |

៥- លោក ជិន ច័ន្ទឆាយា សប្បុរសជន

៦- លោក ម៉េង ដារ័ត្ន សប្បុរសជន

៧- លោកស្រី ណាម គីមលី សប្បុរសជន។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧រោច ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៩ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តកំពង់ឆ្នាំង ចំនួន ៣៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | | |
|---|---|---|---|---|
| ១- | លោក | សូត្រ | សង់ | អភិបាលស្រុកទឹកផុស |
| ២- | លោកស្រី | ជឹម | ចោត | អភិបាលរងស្រុកទឹកផុស |
| ៣- | លោក | មុត | ម៉េង | អភិបាលរងស្រុកជលគិរី |
| ៤- | លោក | ផុន | សីហា | អភិបាលរងស្រុករលាប្អៀរ |

| | | | |
|---|---|---|---|
| ៥- លោក | ឡេង | មាន | អភិបាលរងស្រុកកំពង់លែង |
| ៦- លោក | សាំង | វ៉ាន់ | នាយករដ្ឋបាលស្រុកសាមគ្គីមានជ័យ |
| ៧- លោក | មាន | សម្បត្តិ | ប្រធានការិយាល័យ សាលាខេត្ត |
| ៨- លោក | អ៊ុំ | ច័ន្ទវិសុទ្ធ | ប្រធានការិយាល័យ សាលាខេត្ត |
| ៩- លោក | ហ៊ូ | សុខឌីន | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១០- លោក | សូ | ចន្ទ្រា | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១១- លោក | ញឹល | ចាន់ថេន | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១២- លោកស្រី | សុខ | ភាព | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១៣- លោក | មាស | សារិន | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១៤- លោក | ហ៊ួយ | សុវត្ថិវាសនា | អនុប្រធានការិយាល័យ សាលាខេត្ត |
| ១៥- លោកស្រី | ឃិន | សុភា | មន្ត្រីសាលាខេត្ត |
| ១៦- លោក | មន | ចាន់ថុល | នាយករងរដ្ឋបាលក្រុងកំពង់ឆ្នាំង។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- លោក | ព្រំ | ប៊ុនធឿន | អភិបាលរងស្រុកកំពង់ត្រឡាច |
| ២- លោកស្រី | ទេស | សុវណ្ណា | អភិបាលរងស្រុកជលគិរី |
| ៣- លោក | យន់ | ចំរើន | អភិបាលរងស្រុកជលគិរី |
| ៤- លោក | ទូច | លីហួត | អភិបាលរងក្រុងកំពង់ឆ្នាំង |
| ៥- លោកស្រី | យន | វ៉ៃ | នាយករងរដ្ឋបាលស្រុកកំពង់ត្រឡាច |
| ៦- លោក | មាស | សុផាន់ណា | ប្រធានការិយាល័យ សាលាខេត្ត |
| ៧- លោកស្រី | ណុប | នារីរ័ត្ន | អនុប្រធានការិយាល័យ សាលាខេត្ត |
| ៨- លោកស្រី | លៀង | ម៉ារឌី | អនុប្រធានការិយាល័យ សាលាខេត្ត |
| ៩- លោកស្រី | ស៊ុំ | វល័ក្ខ | ប្រធានការិយាល័យ ស្រុកបរិបូណ៌ |
| ១០- លោក | មួន | គាណាក់ | ប្រធានការិយាល័យ ស្រុកបរិបូណ៌ |
| ១១- លោក | ស៊ុយ | សុខណា | មន្ត្រីសាលាខេត្ត |
| ១២- លោក | អៀម | ឈុន | មន្ត្រីសាលាខេត្ត។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១- លោក | ម៉ៅ | សំណាង | អភិបាលរងក្រុងកំពង់ឆ្នាំង |
| ២- លោក | ហុង | ស៊ុនលី | នាយករដ្ឋបាលស្តីទីស្រុកជលគិរី |
| ៣- លោកស្រី | ចាប | ដានី | អនុប្រធានការិយាល័យ សាលាខេត្ត |
| ៤- លោក | អ៊ូច | វុទ្ធី | ប្រធានការិយាល័យ ស្រុកកំពង់ត្រឡាច |
| ៥- លោក | ងួន | ឌីណា | អនុប្រធានការិយាល័យ សាលាខេត្ត |
| ៦- លោកស្រី | សិត | សធីតា | អនុប្រធានការិយាល័យ សាលាខេត្ត |
| ៧- លោកស្រី | ពេជ្រ | ពានី | មន្ត្រីសាលាខេត្ត |
| ៨- លោកស្រី | រស់ | សុផារ័ត្ន | មន្ត្រីសាលាខេត្ត |

៩- លោកស្រី ម៉ាន ម៉ៅ មន្ត្រីសាលាខេត្ត។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាលដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហេង សួរ** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |

| | | |
|---|---|---|
| ២- ឯកឧត្តម **ម៉ុក ប៉ាន់** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- ឯកឧត្តម **អ៊ុំ ភុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤- ឯកឧត្តម **សែម សុខា** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៥- លោក **សុខ ខេន** | អនុប្រធានទទួលបន្ទុកបណ្តុះបណ្តាល នៃសភាមុខរបរនិងមីក្រូសហគ្រាសកម្ពុជា | អនុប្រធាន |
| ៦- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **គីង ម៉ៅ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨- ឯកឧត្តម **ឡៅ ហ៊ីម** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩- ឯកឧត្តម **រាជ រ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តមសាស្ត្រាចារ្យ **យឹត ស៊ុនណារ៉ា** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១១- ឯកឧត្តម **នួន ពេជ្រនិមិត្ត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- ឯកឧត្តម **ចាន់ សុខុឌ្ឍ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- ឯកឧត្តម **ខឹម ចន្ថា** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៤- លោកជំទាវ **ត្រី ណារល់លីស** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១៥- ឯកឧត្តម **ដួង ចាន់ថាសនា** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៦- ឯកឧត្តម **ព្រហ្ម ដួលីន** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៧- ឯកឧត្តម **អឿង ចន្ថា** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៨- លោកជំទាវ **ហ៊ាន ប៉ូលីណោ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិកា |
| ១៩- ឯកឧត្តម **ខ្វៃ អាទិត្យា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២០- ឯកឧត្តម **ឡា វិបុល** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២១- ឯកឧត្តម **ជា ឧុទ្ធី** | អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២- ឯកឧត្តម **ហ៊ីង ស៊ីដេត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | លេខាធិការ |
| ២៣- ឯកឧត្តម **អាំង សុវណ្ណារ័ត្ន** | អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្ម ទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៤- ឯកឧត្តមឧកញ៉ា **ឡួន ម៉េងតិច** | អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |

២៥- លោកជំទាវ **ម៉ូច ជាច័ន្ទមល្លិកា** ប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិកា

២៦- ឯកឧត្តម **ម៉ិន ភារិន** នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា សមាជិក

២៧- ឯកឧត្តម **យ៉ោក សុទ្ធី** នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស សមាជិក

២៨- លោក **អេង ឈាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងរ៉ែនិងថាមពល សមាជិក

២៩- លោក **ឯម ឬទ្ធី** អគ្គលេខាធិការរងនៃសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា សមាជិក។

**ប្រការ២ .-**

ទទួលស្គាល់តំណាងអង្គការ សង្គមស៊ីវិលឬសមាគម និងក្រុមហ៊ុនឯកជន សម្រាប់ធ្វើជាអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលមានសមាសភាពដូចខាងក្រោម៖

១- ឧកញ៉ា **សុខ ពិសិដ្ឋ** ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា អនុប្រធាន

២- ឧកញ៉ា **តាន់ មុនីវណ្ណា** អគ្គនាយករងក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប សមាជិក

៣- លោក **ប៉ាង ម៉ូនី** នាយកសាលាបច្ចេកទេស ដុនបូស្កូ ភ្នំពេញ សមាជិក

៤- លោក **អេតរ្វេ ថេ** នាយកវិទ្យាស្ថានបណ្តុះបណ្តាលវិស័យកាត់ដេរនៅកម្ពុជា សមាជិក

៥- លោក **ហ៊ី សុធា** ប្រធានថ្នាក់ជាតិនៃសមាគមសណ្ឋាគារកម្ពុជា សមាជិក

៦- លោក **សំ សឿន** ប្រធានសហភាពពលកម្មជាតិកម្ពុជា សមាជិក

៧- លោក **គង់ អាទិត្យ** ប្រធានសហភាពការងារកម្ពុជា សមាជិក

៨- លោកស្រី **ស៊ឹម សុគន្ធា** អគ្គលេខាធិការសហព័ន្ធសហជីពដើម្បីកម្មករ សមាជិកា

៩- លោក **រ៉ូប៊ឺត ខ៊ាង** អនុប្រធានសមាគមរោងចក្រកាត់ដេរ វាយនភ័ណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា សមាជិក

១០- លោកស្រី **គេន នេងឡាង** អនុប្រធានសហភាពចលនាកម្មករកម្ពុជា សមាជិកា

១១- លោក **គ្រីសស្ទៀន ឌីសល័រ** អនុប្រធានទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ សមាជិក

១២- លោកស្រី **ម៉ែន មករា** អគ្គនាយិការងទទួលបន្ទុកផ្នែកអប់រំ នៃអង្គការដើម្បីភាពញញឹមនៃកុមារ សមាជិកា

១៣- លោក **ទុន សុវ័ណ** មន្ត្រីសម្របសម្រួលថ្នាក់ជាតិប្រចាំកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ សមាជិក។

**ប្រការ៣ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣២ សសរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ..០៣.សសរ...**

**សេចក្តីសម្រេច**
**ស្តីពី**
**ការជ្រើសរើស ពលទាហាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**ប្រការ១ :_**

ត្រូវបានអនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើស ពលទាហាន ចំនួន ២.០០២ (ពីរពាន់ពីរ)នាក់ បំពេញក្របខ័ណ្ឌឲ្យកងឯកភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-យោធភូមិភាគទី ១ | ចំនួន | ១១៨ | នាក់ |
| ២-យោធភូមិភាគទី ២ | ចំនួន | ៥៣ | នាក់ |
| ៣-យោធភូមិភាគទី ៣ | ចំនួន | ៨១ | នាក់ |
| ៤-យោធភូមិភាគទី ៤ | ចំនួន | ១០៥ | នាក់ |



៤

| | | |
|---|---|---|
| ៥-យោធភូមិភាគទី ៥ | ចំនួន | ១.១៧៤ នាក់ |
| ៦-យោធភូមិភាគពិសេស | ចំនួន | ១៦៩ នាក់ |
| ៧-កងឯកភាពឈរជើងតាមបណ្ដាកោះ ចំណុះកងទ័ពជើងទឹក | ចំនួន | ៣០០ នាក់ |
| ៨-នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ | ចំនួន | ០២ នាក់ |

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ចន្ទ ១៥ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០៣៥.......សហវ.ប្រក.

# ប្រកាស
## ស្តីពី
## ការបង្កើតអង្គភាពអនុវត្ត គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់ការរៀបចំ និង តាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ៥៧០ សហវ.ប្រក.អគហ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតអង្គភាពអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ ដែលមានសមាសភាព ដូចខាងក្រោម៖

១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជា**នាយកគម្រោង**

២. ឯកឧត្តម **មន្ត ប្រាជ្ញា** អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជា**ប្រធានគ្រប់គ្រងគម្រោង**

៣. លោក **ឈាង យូ** អគ្គនាយករង នៃអគ្គនាយកដ្ឋាន ប.គ.ហ ជា**អនុប្រធានគ្រប់គ្រងគម្រោង**

៤. លោក **មន្ត មុនិន្ទថាវរៈ** ប្រធាននាយកដ្ឋានផែនការ និងកិច្ចការទូទៅ ជា**ប្រធានផ្នែកទទួលបន្ទុកផែនការ និងកិច្ចការទូទៅ**

៥. លោក **ម៉ិន ឆាយ** ប្រធាននាយកដ្ឋានគ្រប់គ្រងធុរកិច្ច ជា**ប្រធានផ្នែកទទួលបន្ទុកគ្រប់គ្រងធុរកិច្ច**

៦. លោក **ខ៉េត គីមស្រាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ជា**ប្រធានផ្នែកទទួលបន្ទុកស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន**

៧. លោក **ភេង សុភារម្យ** ប្រធានការិយាល័យរដ្ឋបាល និងគណនេយ្យ ជា**មន្ត្រីទទួលបន្ទុករដ្ឋបាល និងគណនេយ្យ**

៨. លោកស្រី **ជួន ចាន់ណា** ប្រធានការិយាល័យផែនការ និងគាំទ្រទូទៅ ជា**មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ**

៩. លោក **ហោ សុគន្ធ** ប្រធានការិយាល័យវិភាគមុខងារ ជា**មន្ត្រីទទួលបន្ទុកលទ្ធកម្ម**

១០. លោកស្រី **លីស រ័ត្នចំរ៉ុង** ប្រធានការិយាល័យគ្រប់គ្រងគុណភាព ជា**មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃ**

១១. លោក **ស៊ីន សុខលេង** ប្រធានការិយាល័យសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជា**មន្ត្រីទទួលបន្ទុកបច្ចេកទេស**

១២. មន្ត្រីផ្នែកបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកសកម្មភាពនៃគម្រោង។

**ប្រការ ២.-**

អង្គភាពអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ មានភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង ដែលក្នុងនោះមានជាអាទិ៍៖

- គ្រប់គ្រង តាមដាន និងសម្របសម្រួលរាល់ការអនុវត្តការងារពាក់ព័ន្ធនឹងគម្រោង រួមទាំងបំពេញភារកិច្ចប្រចាំថ្ងៃពាក់ព័ន្ធនឹងការងាររដ្ឋបាលគម្រោង
- គ្រប់គ្រង និងចាត់ចែងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងសម្ភារៈផ្សេងៗ ដែលបម្រើដល់ការអនុវត្តគម្រោង
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោង ដើម្បីស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬពីដៃគូអភិវឌ្ឍន៍ ឱ្យបានទាន់ពេលវេលាកំណត់ ព្រមទាំងតាមដានលទ្ធផលនៃការអនុវត្តថវិកា
- ដឹកនាំ និងអនុវត្តរាល់កិច្ចលទ្ធកម្មសម្រាប់ទំនិញ សេវា និងសំណង់ និងសេវាទីប្រឹក្សា ព្រមទាំងគ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងទៀត, និងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមកាលបរិច្ឆេទដែលបានកំណត់
- សម្របសម្រួលការចុះធ្វើសវនកម្មលើគម្រោង និងចាត់វិធានការកែតម្រូវលើចំណុចខ្វះខាតដែលរកឃើញដោយសវនករ
- ធានាសម្រេចបាននូវលទ្ធផលរបស់គម្រោងទៅតាមពេលវេលា និងធនធានដែលបានកំណត់
- ធានាអនុលោមភាពនៃការអនុវត្តគម្រោងស្របតាមគោលការណ៍ណែនាំ បែបបទ និងនីតិវិធីដែលបានកំណត់ និងឯកភាពជាមួយរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោង និងឯកសារគ្រប់គ្រងគម្រោងពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យការអនុវត្តគម្រោងប្រព្រឹត្តទៅដោយរលូន និងបញ្ចប់ទាន់ពេលវេលា។

**ប្រការ ៣.-**

អង្គភាពអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធផ្សេងៗ ត្រូវដឹកនាំដោយនាយកគម្រោងដែលបំពេញមុខងារជានាយកប្រតិបត្តិ និងបំពេញតួនាទីគ្រប់គ្រង ចាត់ចែង និងត្រួតពិនិត្យការអនុវត្តគម្រោងជារួម និងប្រធានគ្រប់គ្រងគម្រោងដែលមានតួនាទីអនុវត្តសកម្មភាពការងារប្រចាំថ្ងៃរបស់គម្រោង៖

ក. **នាយកគម្រោង** មានភារកិច្ច និងការទទួលខុសត្រូវជាសារវន្ត ដែលក្នុងនោះមានជាអាទិ៍៖

- ធានាប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តគម្រោង ស្របតាមគោលការណ៍ណែនាំ បែបបទ និងនីតិវិធីដែលបានកំណត់ និងឯកភាពជាមួយរាជរដ្ឋាភិបាល
- ចូលរួមជាសមាសភាពហត្ថលេខីក្នុងការបើកគណនីធនាគាររបស់គម្រោង
- ដឹកនាំរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមុនពេលដាក់សំណើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំការប្រជុំប្រចាំត្រីមាស ឬតាមការចាំបាច់ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តចំណាយថវិកា និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពីវឌ្ឍនភាពរបស់គម្រោង

- ពិនិត្យ និងអនុម័តរាល់ការចំណាយ និងដកសាច់ប្រាក់ ដោយប្រើមូលប្បទានបត្រ ឬតាមរយៈការផ្ទេររវាងធនាគារ និងធនាគារ ឬ តាមរយៈការទូទាត់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង អាចប្រគល់ ឬផ្ទេរសិទ្ធិជូនប្រធានគ្រប់គ្រងគម្រោងតាមការចាំបាច់
- ពិនិត្យ និងអនុម័តរាល់ការអនុវត្តនីតិវិធីជម្រះទ្រព្យសម្បត្តិទាំងឡាយរបស់គម្រោង
- ពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឬឆមាស និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់សវនកម្ម
- មានសិទ្ធិចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្មសម្រាប់គ្រប់ការងារអនុវត្តគម្រោង និង អាចប្រគល់ ឬផ្ទេរសិទ្ធិជូនប្រធានគ្រប់គ្រងគម្រោងតាមការចាំបាច់
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោង និងឯកសារគ្រប់គ្រងគម្រោងពាក់ព័ន្ធផ្សេងទៀត។

ខ. **ប្រធានគ្រប់គ្រងគម្រោង** មានភារកិច្ច និងការទទួលខុសត្រូវជាសារវន្ត ដែលក្នុងនោះមានជាអាទិ៍៖

- ធានាសម្រេចបាននូវលទ្ធផលរបស់គម្រោងទៅតាមពេលវេលា និងធនធានដែលបានកំណត់ ដូចបានឯកភាពជាមួយរាជរដ្ឋាភិបាល
- សម្របសម្រួលការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមុនពេលដាក់ជូននាយកគម្រោងពិនិត្យ
- ពិនិត្យរបាយការណ៍សវនកម្ម និងផ្តល់ការឆ្លើយតបចំពោះអនុសាសន៍របស់សវនករ
- ពិនិត្យរាល់ការចំណាយ ដកសាច់ប្រាក់ កិច្ចសន្យា និង ជម្រះទ្រព្យសម្បត្តិ មុនដាក់ស្នើសុំការអនុម័តពីនាយកគម្រោង
- ពិនិត្យ និងអនុម័តរាល់ចំណូលពីគ្រប់ប្រភពហិរញ្ញប្បទានសម្រាប់ការអនុវត្តគម្រោង ដោយមិនគិតពីទំហំទឹកប្រាក់
- មានសិទ្ធិចុះហត្ថលេខាលើលិខិតប្រគល់-ទទួល និង លិខិតបញ្ជាក់ការទទួលយកដំណើរការ នៃទំនិញ សេវា និងសំណង់ និងសេវាទីប្រឹក្សាសម្រាប់ការអនុវត្តកិច្ចសន្យាលទ្ធកម្ម
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់ក្នុងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោង និងឯកសារគ្រប់គ្រងគម្រោងពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ៤.-**

អង្គភាពអនុវត្តគម្រោងមានសិទ្ធិគ្រប់គ្រង និងជ្រើសរើសទីប្រឹក្សា និងក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ សេវា និងសំណង់តាមតម្រូវការចាំបាច់ ដើម្បីគាំទ្រការអនុវត្តគម្រោងឱ្យដំណើរការដោយរលូន។

**ប្រការ ៥.-**

អង្គភាពអនុវត្តគម្រោងបំពេញតួនាទី និងភារកិច្ច និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោង។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា គ.ស. ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៩០.....សហវ.ប្រក.បគហ

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃ ទំនិញ និងសំណង់ និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់ គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គម្រោងពាក់ព័ន្ធផ្សេងៗ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការ-ប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦០៥ សហវ.ប្រក.បគហ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ៧៨៣ សហវ.ប្រក.បគហ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការវាយតម្លៃឯកសារជេញថ្លៃផ្គត់ផ្គង់ឧបករណ៍ សម្ភារ និងសេវាបច្ចេក-វិទ្យាព័ត៌មាន សម្រាប់ការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៧០ សហវ.ប្រក.អគហ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម (Procurement Review Committee) ដែលមានសមាសភាពដូចខាងក្រោម៖

**ក. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតធំ** (Major Procurements)

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **មន្ត ប្រាជ្ញា** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ប.គ.ហ.) | សមាជិក |
| ៣. | លោក **ផាន់ តេត** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៤. | តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) | | សមាជិក |
| ៥. | តំណាង អ.ស.ប. | | សមាជិក។ |

**ខ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតមធ្យម** (General Procurements)

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **មន្ត ប្រាជ្ញា** | អគ្គនាយក នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៣. | លោក **ផាន់ តេត** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៤. | តំណាង អ.ស.ប. | | សមាជិក |
| ៥. | តំណាង អ.ស.ប. | | សមាជិក។ |

**គ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតតូច** (Minor Procurement)

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **មន្ត ប្រាជ្ញា** | អគ្គនាយក នៃអគ្គនាយកដ្ឋាន ប.គ.ហ. | ប្រធាន |
| ២. | លោក **ឈាង យូ** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៣. | តំណាង អ.ស.ប. | | សមាជិក។ |

**ប្រការ២._**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់ (Bid Evaluation Committee) សម្រាប់គ្រប់កម្រិត ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក **ហា សុគន្ធ** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ប.គ.ហ. | ប្រធាន |
| ២. លោកស្រី **ជួន ចាន់ណា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៣. មន្ត្រីផ្នែកបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកសកម្មភាពនៃគម្រោង | | សមាជិក។ |

**ប្រការ៣._**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា (Consultant Evaluation Committee) ដែលមានសមាសភាព ដូចខាងក្រោម៖

**ក. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតធំ និងកម្រិតមធ្យម** (Major and General Procurements)

| | | |
|---|---|---|
| ១. លោក **មន្ត មុនិន្ទថាវរៈ** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋាន ប.គ.ហ. | ប្រធាន |
| ២. លោកស្រី **ជួន ចាន់ណា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ប.គ.ហ. | សមាជិក |
| ៣. តំណាង អ.ស.ប. | | សមាជិក |
| ៤. តំណាង អ.ស.ប. | | សមាជិក |
| ៥. មន្ត្រីផ្នែកបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកសកម្មភាព នៃគម្រោង | | សមាជិក។ |

**ខ. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតតូច** (Minor Procurement)

| | | |
|---|---|---|
| ១. លោកស្រី **ជួន ចាន់ណា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន ប.គ.ហ. | ប្រធាន |
| ២. តំណាង អ.ស.ប. | | សមាជិក |
| ៣. មន្ត្រីផ្នែកបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកសកម្មភាព នៃគម្រោង | | សមាជិក។ |

**ប្រការ៤._**

គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម, គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់, និងគណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា សម្រាប់គម្រោងក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការខ្ចីខ្ចីផ្តល់ពីរដ្ឋ, និងពីមូលបត្ររដ្ឋ បំពេញតួនាទី និងភារកិច្ច និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា គ.ស. ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៦៥...សហវ.ប្រកា.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ ស្ដីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្ដីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមចំណែកជានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដោយមានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ ដើម្បីគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម និងមានគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ជាអង្គភាពអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២
## សិទ្ធិអំណាច ភារកិច្ចទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកា

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិលើវិស័យអប់រំ។

ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផលចំពោះរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពវិស័យអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីកែទម្រង់វិស័យអប់រំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវចូលរួមគាំទ្រ និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកម្រិតមធ្យមសិក្សា ការងារយុវជន ការងារកីឡា និងការងារផ្សេងទៀត ដែលពុំទាន់បានផ្ទេរមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតួនាទីជាសេនាធិការ ឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលជាប្រតិបត្តិករផ្ទាល់លើការគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយ ព្រមទាំងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធជាធរមាន ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

នាយក ឬ ប្រធានគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលជាប្រតិបត្តិករផ្ទាល់ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពខាងលទ្ធផល ចំពោះប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាព ក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយ ព្រមទាំងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធជាធរមាន ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

**ប្រការ៤.**_

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានប្រគល់ និងការគាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម។

នៅក្នុងដំណាក់កាលនៃការរៀបចំថវិកា ដោយផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ និងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានកិច្ចសហការពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវដឹកនាំ និងណែនាំការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមលក្ខខណ្ឌនានា និងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និងស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា។

នៅក្នុងដំណាក់កាលនៃការអនុវត្តថវិកា អភិបាលនៃគណៈអភិបាលក្រុង ស្រុក គឺជាអាណាប័កដើមខ្សែនៃថវិកា ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្ងង់ឥណទានថវិការបស់រដ្ឋបាលក្រុង ស្រុកសាមី។ ដោយឡែក អភិបាលនៃគណៈអភិបាលរាជធានី គឺជាអាណាប័កដើមខ្សែនៃថវិកា ត្រូវចេញសេចក្តីសម្រេចតែងតាំងអភិបាលនៃគណៈអភិបាលខណ្ឌ ជាអាណាប័កផ្ទេរសិទ្ធិនៃថវិកា ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្វង់ឥណទានថវិការបស់រដ្ឋបាលខណ្ឌសាមី។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ នីតិវិធីនៃការអនុវត្តថវិកាដំណើរការការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនីតិវិធីស្តីពីការរៀបចំ និងការអនុវត្តថវិកាសមិទ្ធកម្ម។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលទទួលសាច់ប្រាក់ពីរតនាគាររាជធានី ខេត្ត តាមរយៈគណនីធនាគាររបស់ខ្លួន ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលទទួលសាច់ប្រាក់ពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

## ជំពូកទី៣
## ការរៀបចំគម្រោងថវិកា

**ប្រការ៥._**

កញ្ចប់ថវិកា រួមទាំងចំណាយបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងកញ្ចប់ថវិកា រួមទាំងចំណាយបន្ទុកបុគ្គលិក របស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវបានគ្រោងជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ពិភាក្សាភ្ជាប់គ្នាជាមួយនឹងគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ព្រមទាំងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

ដើម្បីធានាដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព នៅក្នុងត្រីមាសទី១ នៃឆ្នាំនីមួយៗ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា អំពីតម្រូវការគ្រូបង្រៀន និងបុគ្គលិកអប់រំ ព្រមទាំងតម្រូវការនៃការបណ្តុះបណ្តាលគ្រូ និងបុគ្គលិកអប់រំដែលកំពុងបម្រើការនៅតាមសាលារៀន មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងនៅតាមការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យអប់រំ ការជ្រើសរើស និងការបែងចែកគ្រូ និងបុគ្គលិកអប់រំ រួមទាំងការផ្តល់ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលបន្ត។

កញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ត្រូវគ្រោងផ្អែកតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ត្រូវគ្រោងទៅតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមទាំងចំណាយបន្ទុកបុគ្គលិក ក្នុងការគាំទ្រការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ត្រូវគ្រោងផ្អែកតាមតម្រូវការចំណាយជាក់ស្តែង និងក្នុងកម្រិតពិតានចំណាយដែលបានកំណត់។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងចំណាយមិនមែនបន្ទុកបុគ្គលិក ក្នុងអនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត)។

**ប្រការ៦._**

ដំណើរការនៃការរៀបចំថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំរួមគ្នា ស្របតាមប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាសង្គតិភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយវិស័យអប់រំ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកសម្របសម្រួល បូកសរុប និងរៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ក្រោមការដឹកនាំ និងការណែនាំរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងដោយមានការគាំទ្របច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡា រួចបញ្ជូនទៅសុំការពិនិត្យ និងឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មុននឹងដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើគម្រោងថវិកានេះ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ជូនក្រសួងអប់រំ យុវជន និងកីឡា១ (មួយ) ច្បាប់ ដើម្បីពិនិត្យសង្គតិភាពឱ្យស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ បែបបទនៃការរៀបចំផែនការសកម្មភាពអប់រំ យុវជន និងកីឡា និងរចនាសម្ព័ន្ធកម្មវិធីដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និង១ (មួយ) ច្បាប់ទៀត ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យការផ្សារភ្ជាប់គម្រោងថវិកានេះ ជាមួយគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងមូល។

សំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវដាក់ពិភាក្សាការពាររួមគ្នាជាមួយនឹងសំណើគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងថវិការដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា។ កិច្ចពិភាក្សាការពារគម្រោងថវិកានេះ នឹងប្រព្រឹត្តទៅជា ២ (ពីរ) កម្រិត រួមមាន កម្រិតបច្ចេកទេស ដែលត្រូវរៀបចំ និងដឹកនាំដោយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានថវិកា និងកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ដែលត្រូវដឹកនាំដោយថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដើម្បីពិនិត្យផ្តល់កញ្ចប់ថវិកាទៅតាមលទ្ធភាពថវិកាជាតិប្រចាំឆ្នាំក្នុងក្របខ័ណ្ឌនៃថវិកាវិស័យអប់រំ ព្រមទាំងក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

គម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវផ្តល់ជូនផ្អែកតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្នុងករណីមានការសម្រេចដោយឡែកពាក់ព័ន្ធនឹងការកាត់បន្ថយ ឬបង្កើនទំហំថវិកា ទៅតាមលទ្ធភាព និងភាពទ្រទ្រង់បាននៃថវិកាប្រចាំឆ្នាំ លើសំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរតាមការចាំបាច់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៧._**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវបានរៀបចំលម្អិតជាសៀវភៅថវិកា តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជូនទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្ត និងសម្រាប់ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា ព្រមទាំងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីតាមដានការអនុវត្តក្នុងក្របខ័ណ្ឌវិស័យអប់រំ។

បន្ថែមពីលើធនធានហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទទួលបានពីថវិកាថ្នាក់ជាតិតាមលទ្ធភាពថវិកាប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាវិស័យអប់រំ រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចប្រើប្រាស់ចំណែកធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌ ចំណែកធនធានដែលទទួលបានពីថវិការាជធានី និងធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់គាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានបែងចែកលម្អិតទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ដូចមានចែងក្នុងសៀវភៅថវិកាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តឱ្យបានទាន់ពេលវេលាចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំថវិកា។

## ជំពូកទី៤
## នីតិវិធីនៃការអនុវត្តថវិកា
## ផ្នែកទី១
## ការបើកសាច់ប្រាក់

**ប្រការ៨.-**

ថវិកាចំណាយមិនមែនបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបើកផ្តល់សាច់ប្រាក់មុន។

ការបើកផ្តល់សាច់ប្រាក់មុន គឺជានីតិវិធីដែលតម្រូវឱ្យផ្តល់សាច់ប្រាក់ជាមុនចំនួន១០០% (មួយរយភាគរយ) ដែលត្រូវបើកផ្តល់ចំនួន២ (ពីរ) លើក ក្នុង១ ឆ្នាំ គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនា នៃឆ្នាំនីមួយៗ។ កម្មវិធីចំណាយប្រចាំត្រីមាស ត្រូវរៀបចំឡើងដោយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បន្ទាប់មកបញ្ជូនទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ពិនិត្យ និងដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច និងបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបូកសរុប និងផ្ញើមកអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីចំណាយប្រចាំត្រីមាស ត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់ចំណាយតាមត្រីមាសនីមួយៗ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ១ (មួយ) រូប ជាមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីកាន់កាប់សាច់ប្រាក់ដែលបានបើកផ្តល់ឱ្យមុន សម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- ចូលរួមក្នុងដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំមូលប្បទានប័ត្រដក ឬបញ្ជាផ្ទេរប្រាក់ពីធនាគារដើម្បីដាក់ជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងសម្រេច
- ដកសាច់ប្រាក់ពីគណនីនៅធនាគារ និងរក្សាសាច់ប្រាក់ទុកក្នុងបេឡា
- កាន់បញ្ជីតាមដានប្រាក់ក្នុងធនាគារ និងបញ្ជីបេឡា
- រៀបចំបណ្ណចំណូល និងបណ្ណចំណាយ ដាក់ជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌពិនិត្យ និងសម្រេចតាមឋានានុក្រម
- បើកសាច់ប្រាក់ ឬផ្ទេរប្រាក់ជូនអ្នកស្នើសុំ ផ្អែកតាមសំណើចំណាយថវិកា
- រៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងសកម្មភាព និងរបាយការណ៍ទូទាត់ចំណាយថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ

- រៀបចំទុកដាក់ឯកសារ ឬសក្ខីបត្រចំណាយលើការគាំទ្រផ្សេងៗពាក់ព័ន្ធនឹងការចំណាយថវិកាសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់ជាកម្មវត្ថុនៃការតាមដាន អធិការកិច្ច និងសវនកម្ម
- ទទួលខុសត្រូវជាលក្ខណៈបុគ្គល និងប្រាក់កាស ដោយមិនទាន់គិតដល់ទណ្ឌកម្មរដ្ឋបាល ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ចំពោះការថែរក្សាការពារមូលនិធិដែលខ្លួនទទួលបាន ឬបានចំណាយ ការរក្សាទុកដាក់លិខិតយុត្តិការ និងការកត់ត្រាបញ្ជីគណនេយ្យ។

បន្ថែមពីនេះ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- ចូលរួមរៀបចំ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ចូលរួមរៀបចំ និងបូកសរុបកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- ប្រមូល និងរៀបចំរបាយការណ៍បូកសរុបទូទាត់ចំណាយថវិការបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- ផ្តល់ការគាំទ្រ និងសហការក្នុងដំណើរការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មលើការចំណាយថវិការបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៩._**

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសំណើសុំបើកសាច់ប្រាក់មុនតាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន។

**ប្រការ១០._**

រតនាគាររាជធានី ខេត្ត ត្រូវបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

វេតនាគាររាជធានី ខេត្ត ត្រូវបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ តាមពេលកំណត់ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុញ្ញាតឱ្យគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បន្តប្រើប្រាស់គណនីនៅធនាគារដៃគូដែលមានស្រាប់ សម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន។ ដោយឡែក គ្រឹះស្ថានសិក្សាសាធារណៈ ដែលត្រូវបានបង្កើតថ្មី និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានតម្រូវការគណនីធនាគារសម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន អាចបើកគណនីនៅតាមធនាគារដៃគូណាមួយសមស្រប បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតបើកគណនីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈក្រសួងអប់រំ យុវជន និងកីឡា។

## ផ្នែកទី២
## ការគ្រប់គ្រងសាច់ប្រាក់

**ប្រការ១១**._

នៅពេលដែលបានទទួលសាច់ប្រាក់ គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រជុំផ្សព្វផ្សាយ និងបិទផ្សាយលើបញ្ជាព័ត៌មានជូនដល់លោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ នូវព័ត៌មានអំពីចំនួនទឹកប្រាក់ដែលបានទទួល និងគម្រោងចំណាយប្រចាំត្រីមាស។

**ប្រការ១២**._

គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (គ.ម.ស) របស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ត្រូវសហការចាត់ចែង គ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

នាយក ឬប្រធានគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

## ផ្នែកទី៣
## នីតិវិធីចលនាឥណទានថវិកា

**ប្រការ១៣._**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តចំណាយមិនលើសពីទំហំឥណទានថវិកាដែលបានបែងចែកតាមសៀវភៅថវិកាប្រចាំឆ្នាំឡើយ លើកលែងតែមានការបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាដែលត្រូវបានអនុញ្ញាតចាប់ពីដើមត្រីមាសទី២។

**ប្រការ១៤._**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើសំណើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សម្រាប់ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងក្រុង ស្រុក ខណ្ឌតែមួយ ក្នុងជំពូកតែមួយ នៃចង្កោមសកម្មភាពតែមួយ។

**ប្រការ១៥._**

រដ្ឋបាលក្រុង ស្រុក ត្រូវធ្វើសំណើមកអគ្គនាយកដ្ឋានថវិកា និងចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការស្នើសុំបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច។

រដ្ឋបាលខណ្ឌ ត្រូវធ្វើសំណើមកអគ្គនាយកដ្ឋានថវិកា តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ និងចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការស្នើសុំបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច។

ការធ្វើនិយ័តកម្មឥណទានថវិកាក្នុងលក្ខខណ្ឌដែលមិនត្រូវបានធ្វើប្រតិភូកម្មអំណាច រួមមាន៖

១-ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងក្រុង ស្រុក ខណ្ឌតែមួយ ពីជំពូកមួយ ទៅជំពូកមួយទៀត និង/ឬ ពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយទៀត។

២-ការធ្វើនិយ័តកម្មឥណទានថវិកាក្នុងអនុគណនី ៦៤០២៣ (ប្រាក់បំណាច់ម៉ោងបន្ថែម) អនុគណនី ៦៤០២៦ (ប្រាក់បំណាច់តំបន់) និងអនុគណនី ៦៤០៤១ (បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា)។

ការបន្ថែមឥណទានថវិកា និងការធ្វើនិយ័តកម្មឥណទានថវិកាខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## ការទូទាត់ និងកិច្ចបញ្ជិកាគណនេយ្យ

**ប្រការ១៦._**

ហេរញ្ញិករបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវកាន់បញ្ជីតាមដានសាច់ប្រាក់នៅធនាគារ និងបញ្ជីបេឡា។

ហេរញ្ញិករបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយរួមមានៈ លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗ និងបណ្ណចំណាយ ដើម្បីរៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី និងអនុគណនី ជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លិខិតយុត្តិការ និងសក្ខីបត្រច្បាប់ដើមទាំងនោះ ត្រូវរក្សាទុកនៅអង្គភាពដើម សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយចំណាយ។

ហេរញ្ញិករបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយ ដើម្បីរៀបចំរបាយការណ៍ចំណាយជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវប្រមូលរបាយការណ៍ទូទាត់ចំណាយថវិកាពីគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត មណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ នៅតាមក្រុង ស្រុក ខណ្ឌ និងចំណាយគាំទ្រផ្នែករដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំបូកសរុបជាតារាងរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី អនុគណនី ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រួចជូនទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ។ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម ដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ចុះហត្ថលេខា រួចបញ្ជូនទៅរតនាគារខេត្ត ដើម្បីពិនិត្យ និងទូទាត់ជម្រះបញ្ជី។ ការិយាល័យផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋបាលខណ្ឌ ត្រូវរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម ដាក់ជូនអភិបាលនៃគណៈអភិបាលខណ្ឌចុះហត្ថលេខា រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ដើម្បីត្រួតពិនិត្យថវិកា និងបញ្ជូនទៅរតនាគាររាជធានី ដើម្បីទូទាត់ជម្រះបញ្ជី។ ឯកសារដែលត្រូវភ្ជាប់ជាមួយ មានដូចខាងក្រោមៈ

- លិខិតស្នើសុំទូទាត់ថវិកា
- សាលាកបត្រកត់ត្រាចំណាយនិងត្រួតពិនិត្យហិរញ្ញវត្ថុ
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិនិយ័តកម្ម
- អាណត្តិនិយ័តកម្ម
- និងរបាយការណ៍ទូទាត់ចំណាយថវិកា (ជំពូក គណនី អនុគណនី) ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៧._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និង

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់នៅសល់ចុងឆ្នាំសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។ ក្នុងករណីមានសាច់ប្រាក់នៅសល់ចុងឆ្នាំ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបង់ប្រាក់ចូលគណនីធនាគាររបស់រតនាគាររាជធានី ខេត្តវិញ យ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ ហើយផ្អែកតាមប្រកាសពីធនាគារដែលទទួលបាន ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុប និងបញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន ទៅរតនាគាររាជធានី ខេត្ត។

**ប្រការ១៨._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យ អប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកត់ត្រាចំណូល ចំណាយ ក្នុងបញ្ជីមួយចំនួនដូចខាងក្រោម៖

- បញ្ជីតាមដានសាច់ប្រាក់នៅធនាគារ (កត់ត្រាដោយយោងតាមរបាយការណ៍របស់ធនាគារ ឬបណ្ណបង់ប្រាក់ បណ្ណដកប្រាក់ ឬ ប្រកាសឥណពន្ធ ប្រកាសឥណទាន)
- បញ្ជីបេឡា (កត់ត្រាដោយយោងតាមបណ្ណចំណូល បណ្ណចំណាយ)
- បញ្ជីសម្ភារៈ (បណ្ណបញ្ចូលសម្ភារៈទំនិញ បណ្ណបញ្ចេញសម្ភារៈទំនិញ និងបញ្ជីវិភាគសម្ភារៈទំនិញ)។

**ប្រការ១៩._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចេញសារាចរស្តីពីកិច្ចបញ្ជិកាគណនេយ្យ លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ និងការគាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយពិគ្រោះយោបល់ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការរៀបចំរបាយការណ៍

**ប្រការ២០._**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ចំណាយថវិកា និងរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ តាមយន្តការ បែបបទ និងនីតិវិធីជាធរមាន។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបរបាយការណ៍ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ តាមទម្រង់របាយការណ៍ដែលបានកំណត់ និងបញ្ជូនមកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងហិរញ្ញវត្ថុនៃរដ្ឋបាលខណ្ឌ ដើម្បីដាក់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងសម្រេច។ របាយការណ៍ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មនេះ ត្រូវផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត ចំនួន ១ (មួយ) ច្បាប់ និងជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន ១ (មួយ) ច្បាប់ ដើម្បីបូកសរុប និងផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡា ឱ្យទាន់ពេលវេលាកំណត់។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ចូលរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមទម្រង់ បែបបទ និងនីតិវិធីកំណត់។

**ប្រការ២១._**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដោយពិគ្រោះយោបល់ជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ២២._**

កញ្ចប់ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់គាំទ្រផ្នែករដ្ឋបាលក្នុងការអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីនៃប្រកាសនេះ ចាប់ពីឆ្នាំថវិកា២០២៥ តទៅ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ទំព័រទី១៤

**ប្រការ២៤.**_

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាព ពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រមទាំងគ្រប់ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអង្គភាពក្រោមឱវាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០២៤

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **ក្រសួងអប់រំ យុវជន និងកីឡា** | **ក្រសួងមហាផ្ទៃ** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** | **អភិសន្តិបណ្ឌិត ស សុខា** |

**កន្លែងទទួល៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមុខងារសាធារណៈ
- -ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -លេខាធិការដ្ឋាន គ.ជ.អ.ប
- -រដ្ឋបាលរាជធានី ខេត្ត
- -ដូចប្រការ២៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ៤៧៤ ... [illegible] ... ប្រក

ថ្ងៃ ......... ខែ ......... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ របស់ ក្រុមហ៊ុន លី លី ហ្វ៊ូដ អ៊ិនដាសទ្រី ខូអិលធីឌី

## <u>សម្រេច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឱ្យក្រុមហ៊ុន **លី លី ហ្វ៊ូដ អ៊ិនដាសទ្រី ខូអិលធីឌី (LY LY FOOD INDUSTRY CO., LTD.)** តំណាងដោយលោកស្រី **តែម មុំ** សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ **010885143 (02)** ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បង្កើតរោងចក្រផលិតនំស្រួយ ទឹកដោះគោជូរ ទឹកសុទ្ធ ភេសជ្ជៈគ្រប់ប្រភេទ នំគ្រប់ប្រភេទ ស្ករគ្រាប់ បន្លែផ្លែឈើក្រៀម មី គុយទាវក្រៀម នំបញ្ចុកក្រៀម ស្រាកែច្នៃ ក្រដាសជូតមាត់ ក្រដាសរាម ក្រដាសវេចខ្ចប់ និងសំបកវេចខ្ចប់ប្រភេទប្លាស្ទិច ជ័រ ដែលមានទីតាំងស្ថិតនៅអគារលេខ២៨១ ផ្លូវចូលវត្តតាំងកសាង ភូមិក្បាលដំរី១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| ១-នំស្រួយ នំគ្រប់ប្រភេទ | ១០៧១ |
| ២-ទឹកដោះគោជូរ | ១០៥០ |
| ៣-ទឹកសុទ្ធ ភេសជ្ជៈគ្រប់ប្រភេទ | ១១០៤ |
| ៤-ស្ករគ្រាប់ | ១០៧៣ |
| ៥-បន្លែផ្លែឈើក្រៀម | ១០៣០ |
| ៦-មី គុយទាវក្រៀម នំបញ្ចុកក្រៀម | ១០៧៤ |
| ៧-ស្រាកែច្នៃ | ១១០១ |
| ៨-ក្រដាសជូតមាត់ ក្រដាសរាម ក្រដាសវេចខ្ចប់ | ១៧០៩ |
| ៩-សំបកវេចខ្ចប់ប្រភេទប្លាស្ទិច ជ័រ | ២២២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពី ការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតនំស្រួយ ទឹកដោះគោជូរ ទឹកសុទ្ធ ភេសជ្ជៈគ្រប់ប្រភេទ នំគ្រប់ប្រភេទ ស្ករគ្រាប់ បន្លែផ្លែឈើក្រៀម មី គុយទាវក្រៀម នំបញ្ចុកក្រៀម ស្រាកែច្នៃ ក្រដាសជូតមាត់ ក្រដាសរាម ក្រដាសវេចខ្ចប់ និងសំបកវេចខ្ចប់ប្រភេទប្លាស្ទិច ជ័រ លី លី ហ្វ៊ូដ អ៊ិនដាសទ្រី ខូអិលធីឌី** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាព ឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់ រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការ គ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៣១៥ ឧវបន.កឧ.ប្រក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ និងលិខិតលេខ ១៦៧៨ ឧវបន.កឧ.លស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការពង្រីកបន្ថែមមុខសញ្ញាផលិតកម្មរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹខ ស៊ីនី

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ:.......................................

ថ្ងៃ.......................... ខែ.............. ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ.......... ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៧១២/២៤ គ.វ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតរោងចក្រផលិតតុក្កតា និងសម្ភារសត្វចិញ្ចឹម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ២៦៦៥/២៤ គ.វ.ក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការប្តូរនាមករណ៍ និងតម្កល់លក្ខន្តិកៈថ្មី របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន ផផ្លាស ផេត សឺបផ្លាយ (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ផផ្លាស ផេត សឺបផ្លាយ (ខេមបូឌា) ឯ.ក **(PAWPLUS PET SUPPLIES (CAMBODIA) CO., LTD.)** តំណាងដោយលោក **HE, WEIPING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EC1819902** ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ បង្កើតរោងចក្រផលិតតុក្កតា និងសម្ភារសត្វចិញ្ចឹម ដែលមានទីតាំងស្ថិតនៅសួនឧស្សាហកម្ម ហ្គ្រេន បូកគោ (អគារលេខ **I-4A-09** ភូមិព្រែកសង្កែ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ១-តុក្កតា | ៣២៤០ |
| ២-សម្ភារសត្វចិញ្ចឹម | ៣២៩០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតតុក្កតា និងសម្ភារសត្វចិញ្ចឹម ផង្គាស ផេត ស៊ីបផ្លាយ (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២៩០ ឧវបន.កឧ.ប្រក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ និងលិខិតលេខ៦១២៣ ឧវបន.កឧ.លស ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ស្តីពីការប្តូរនាមករណ៍ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**បណ្ឌិត ទីវ ស៊ីនី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -សាលាខេត្តព្រះសីហនុ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
- -រដ្ឋបាលស្រុកព្រៃនប់
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៥២៦ ... ឧ.វ.ប.ន ... ក.ក ... ប្រក

ថ្ងៃ ពុធ ១២ កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៣៥៧៨/២៤ គ.វ.ក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតរោងចក្រផលិតគ្រឿងសង្ហារិម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតគ្រឿងសង្ហារិម ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន ជាំងស៊ូ សេងបាង ហ្គាឌិន ហ្វើនីឈ័រ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជាំងស៊ូ សេងបាង ហ្គាឌិន ហ្វើនីឈ័រ ឯ.ក (**JIANGSU SHENGBANG GARDEN FURNITURE CO., LTD.**) តំណាងដោយលោក **FAN, DONGCHENG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EL9938013** ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ បង្កើតរោងចក្រផលិតគ្រឿងសង្ហារិម ដែលមានទីតាំងស្ថិតនៅភូមិពូនភ្នំ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
| --- | --- |
| គ្រឿងសង្ហារិម | ៣១០០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតគ្រឿងសង្ហារិម ជាំងស៊ូ សេងបាង ហ្គាឌិន ហ្វើនីឈើរ ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានទាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

